


ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# របាយការណ៍ស្ដីពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុប្រចាំឆ្នាំ ២០១៩

ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

ស្ថានភាពនិងការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុ

ទំនាក់ទំនងម៉ាក្រូហិរញ្ញវត្ថុ និងហានិភ័យប្រឈមចំពោះស្ថិរភាពហិរញ្ញវត្ថុ

# មាតិកា


**អារម្ភកថា**..........................................................................................................២
**ខ្លឹមសារសង្ខេប**.....................................................................................................៤
**១. ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច** ...........................................................................៦
**១.១ ស្ថានភាពនិងស្ថិរភាពវិស័យខាងក្រៅ**...........................................................................៦
ក- ស្ថានភាពវិស័យខាងក្រៅ ..............................................................................................៦
ខ- ស្ថិតិជញ្ជីងទូទាត់ ........................................................................................................៦
គ- អត្រាប្តូរប្រាក់ និងស្ថិរភាពវិស័យខាងក្រៅ..........................................................................១១
**១.២ ស្ថានភាពនិងស្ថិរភាពសេដ្ឋកិច្ចកម្ពុជា**..........................................................................១២
ក- កំណើនសេដ្ឋកិច្ច និងអតិផរណា......................................................................................១២
ខ- វិស័យរូបិយវត្ថុ ...........................................................................................................១៤
គ- វិស័យសារពើពន្ធ ........................................................................................................១៦
ឃ- វិស័យសំណង់និងអចលនទ្រព្យ.......................................................................................១៨
**២. ស្ថានភាពនិងការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុ** ......................................................................២១
**២.១ ទិដ្ឋភាពទូទៅ ស្ថានភាព និងការវាយតម្លៃប្រព័ន្ធធនាគារ** ......................................................២១
ក- ទិដ្ឋភាពទូទៅប្រព័ន្ធធនាគារ .........................................................................................២១
ខ- លទ្ធភាពស្វែងរកប្រាក់ចំណេញ ......................................................................................២៣
គ- ស្ថានភាពដើមទុន ......................................................................................................២៥
ឃ- ស្ថានភាពសន្ទនីយភាពនិងការផ្តល់ហិរញ្ញប្បទាន ...............................................................២៥
ង- គុណភាពឥណទាន ......................................................................................................២៧
**២.២ ការអភិវឌ្ឍវិស័យមូលបត្រនិងវិស័យធានារ៉ាប់រង** ...............................................................២៧
ក- ផ្សារមូលបត្រ..............................................................................................................២៧
ខ- ផ្សារមូលបត្របំណុល......................................................................................................២៨
គ- វិស័យធានារ៉ាប់រង .........................................................................................................២៩
**៣. ទំនាក់ទំនងម៉ាក្រូហិរញ្ញវត្ថុ និងហានិភ័យប្រឈមចំពោះស្ថិរភាពហិរញ្ញវត្ថុ**........................................៣១
**៣.១ ការវិភាគតាមតារាងតុល្យការ**...........................................................................................៣១
**៣.២ កំណើនឥណទាន** ..........................................................................................................៣៣
ក- កំណើនឥណទាន និងគម្លាតឥណទានធៀបនឹងផ.ស.ស...........................................................៣៣
ខ. ឥណទានតាមវិស័យ .......................................................................................................៣៤
គ. គុណភាពឥណទានតាមវិស័យ...........................................................................................៣៩
**៣.៣ វិធានការម៉ាក្រូប្រុងប្រយ័ត្ន**...............................................................................................៤១
**៣.៤ ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចនិងវិស័យធនាគារ**.....................................................................៤២
**ឧបសម្ព័ន្ធ**

# អារម្ភកថា

នៅឆ្នាំ២០១៩ ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាបានប្រឈមនឹងហានិភ័យមួយចំនួនទាំងពីកត្តាខាងក្រៅ និងខាងក្នុង។ ចំពោះហានិភ័យខាងក្រៅ ភាពមិនច្បាស់លាស់និងការអូសបន្លាយនៃភាពតានតឹងពាណិជ្ជកម្ម និងកំណើនយឺតជាងការរំពឹងទុកនៃសេដ្ឋកិច្ចចិន បានធ្វើឱ្យកំណើនសេដ្ឋកិច្ចពិភពលោកមានកម្រិតទាបជាងមុន។ ហានិភ័យទាំងនេះបានដាក់សម្ពាធដល់សេដ្ឋកិច្ចកម្ពុជាដែលពឹងផ្អែកលើការនាំចេញនិងវិស័យទេសចរណ៍។ កំណើនការនាំចេញនិងភ្ញៀវទេសចរអន្តរជាតិបានថមថយ ហើយកំណើនឥណទានទៅកាន់វិស័យកម្មន្តសាលនិងវិស័យទេសចរណ៍ក៏បានបង្ហាញសញ្ញាថយចុះផងដែរ។ ហានិភ័យខាងក្នុងចំពោះសេដ្ឋកិច្ច រួមមាន ភាពមិនប្រាកដប្រជាចំពោះការដកប្រព័ន្ធអនុគ្រោះពន្ធអ្វីៗគ្រប់យ៉ាងលើកលែងសព្វាវុធពីសហភាពអឺរ៉ុប និងវត្តមាននៃការផ្តល់ប្រាក់កម្ចីដោយផ្ទាល់ពីក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យមួយចំនួនដោយមិនមានការត្រួតពិនិត្យ គួបផ្សំនឹងកំណើនឥណទានយ៉ាងឆាប់រហ័សទៅកាន់វិស័យសំណង់និងអចលនទ្រព្យ។ ទោះបីជួបប្រទះនឹងបញ្ហាប្រឈមទាំងនេះ សេដ្ឋកិច្ចកម្ពុជានៅតែរក្សាបានកំណើនខ្ពស់ប្រកបដោយចីរភាពក្នុងអត្រា ៧% ជាមួយនឹងកម្រិតទាបនៃអតិផរណានិងស្ថិរភាពអត្រាប្តូរប្រាក់ ហើយប្រព័ន្ធហិរញ្ញវត្ថុបន្តមានស្ថិរភាពនិងភាពរឹងមាំ ដោយការរីកចម្រើននិងភាពស៊ីជម្រៅកាន់តែខ្លាំងនៃវិស័យធនាគារ។ ភាពរឹងមាំនៃវិស័យធនាគារនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈសុខុមាលភាពល្អរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គួបផ្សំនឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការម៉ាក្រូប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងហានិភ័យនិងពង្រឹងប្រព័ន្ធធនាគារ។

សម្រាប់ឆ្នាំ២០២០ សេដ្ឋកិច្ចកម្ពុជាក៏ដូចជាវិស័យហិរញ្ញវត្ថុអាចប្រឈមនឹងភាពមិនច្បាស់លាស់ខ្ពស់។ ការរីករាលដាលនៃជំងឺកូវីដ១៩បាននាំឱ្យមូលនិធិរូបិយវត្ថុអន្តរជាតិវាយតម្លៃកំណើនសេដ្ឋកិច្ចពិភពលោកឡើងវិញដោយទម្លាក់ពី ៣,៣% ទៅ -៣% ហើយសេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងថយចុះស្របពេលដែលសសរស្តម្ភនៃកំណើនសេដ្ឋកិច្ចបាននិងកំពុងរងផលប៉ះពាល់ ដូចជា វិស័យទេសចរណ៍ ការនាំចេញ និងវិស័យសំណង់។ ក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជាបន្តតាមដានយ៉ាងប្រុងប្រយ័ត្នចំពោះវិស័យដែលរងផលប៉ះពាល់ ព្រមទាំងបានវាយតម្លៃលើស្ថានភាពសន្ទនីយភាព ភាពគ្រប់គ្រាន់នៃដើមទុន និងហានិភ័យផ្សេងៗទៀតរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយបានធ្វើការយ៉ាងជិតស្និទ្ធជាមួយសមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងអាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធដទៃទៀត។ ដោយសារវិស័យធនាគារកម្ពុជាមានមូលដ្ឋានដើមទុននិងសន្ទនីយភាពប្រកបដោយភាពរឹងមាំអស់រយៈពេលជាងមួយទសវត្សរ៍ ប្រព័ន្ធហិរញ្ញវត្ថុនៅឆ្នាំ២០២០ ត្រូវបានរំពឹងថានឹងមានភាពធន់អាចទប់ទល់នឹងហានិភ័យនានាបាន។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាមានគោលនយោបាយនិងវិធានការត្រៀមទុកជាស្រេចក្នុងការគ្រប់គ្រងផលប៉ះពាល់មកលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាពិសេសបន្តតាមដានហានិភ័យនៅក្នុងវិស័យធនាគារ ក៏ដូចជាគាំទ្រវិធានការរបស់រាជរដ្ឋាភិបាល

កម្ពុជាក្នុងការទប់ទល់នឹងវិបត្តិដែលមិនធ្លាប់មានពីមុនមក។ ទោះយ៉ាងណា កម្រិតខ្ពស់នៃដុល្លារូបនីយកម្មនៅតែជាបញ្ហាប្រឈមនិងបានដាក់កម្រិតលើលទ្ធភាពរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការដើរតួនាទីជាអ្នកឱ្យខ្ចីចុងក្រោយ និងរឹតត្បិតប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ។

ខ្ញុំសង្ឃឹមថា របាយការណ៍ស្តីពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ ឆ្នាំ២០១៩ នឹងផ្តល់ព័ត៌មានដែលមានប្រយោជន៍អំពីស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជា ហានិភ័យចម្បងៗ និងវិធានការគោលនយោបាយនានាសម្រាប់អ្នករៀបចំគោលនយោបាយ ក្នុងគោលដៅលើកកម្ពស់ស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះភាគីពាក់ព័ន្ធទាំងអស់ក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ដែលកន្លងមកបានចូលរួមចំណែកយ៉ាងសកម្មដល់កំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព។

ថ្ងៃសុក្រ ១កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០

**ជា ចាន់តូ**

**ទេសាភិបាល**

**ធនាគារជាតិនៃកម្ពុជា**

# ខ្លឹមសារសង្ខេប


ការថមថយកំណើនសេដ្ឋកិច្ចពិភពលោក បានធ្វើឱ្យប៉ះពាល់ដល់តម្រូវការខាងក្រៅលើទំនិញ និងសេវារបស់កម្ពុជា។ ការនាំចេញទំនិញដែលគាំទ្រជាចម្បងដោយ សម្លៀកបំពាក់ ស្បែកជើង គ្រឿងអេឡិចត្រូនិក និងគ្រឿងបន្លាស់យានយន្ត មានកំណើនថមថយបន្តិច ប៉ុន្តែត្រូវបានធ្វើពិពិធកម្មជាបន្តបន្ទាប់។ ជញ្ជីងពាណិជ្ជកម្មបន្តមានឱនភាព ដោយសារការកើនឡើងខ្ពស់នៃការនាំចូលវត្ថុធាតុដើម ជាពិសេសសម្ភារសំណង់ និងប្រេងឥន្ធនៈ ដែលគាំទ្រដោយតម្រូវការក្នុងស្រុក។ ទន្ទឹមនេះ វិស័យទេសចរណ៍បានថមថយកំណើនជាងមុន ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១៩មក ដោយសារការថយចុះកំណើនភ្ញៀវទេសចរអន្តរជាតិ ជាពិសេសភ្ញៀវទេសចរចិន ជាមួយនឹងនិន្នាការថយចុះនៃភ្ញៀវទេសចរដទៃទៀត។

លក្ខខណ្ឌអំណោយផលនៃទីផ្សារហិរញ្ញវត្ថុពិភពលោក បានគាំទ្រដល់លំហូរចូលមូលធន ដែលធ្វើឱ្យកម្ពុជាអាចគរពូនទុនបម្រុងអន្តរជាតិបានក្នុងកម្រិតខ្ពស់។ លំហូរវិនិយោគផ្ទាល់បរទេសបន្តមានភាពរឹងមាំ ជាពិសេសទៅក្នុងវិស័យហិរញ្ញវត្ថុ សំណង់ និងកម្មន្តសាល ដែលផាត់ទាត់ឱនភាពគណនីចរន្តបានទាំងស្រុង។ ប្រទេសចិនមានចំណែកធំជាងគេក្នុងការវិនិយោគផ្ទាល់បរទេសមកកម្ពុជាដែលមានទំហំជិត ៥០% នៃការវិនិយោគផ្ទាល់បរទេសសរុប។ បំណុលក្រៅប្រទេសសរុបបានបន្តកើនឡើង ដោយសារកំណើនការខ្ចីពីបរទេសរបស់គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ខណៈដែលបំណុលសាធារណៈខាងក្រៅធៀបនឹងផលិតផលក្នុងស្រុកសរុបបានថយចុះ។ វិស័យខាងក្រៅបន្តមានស្ថិរភាពរឹងមាំ ជាមួយនឹងកម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិ ដែលអាចធានាការនាំចូលនៅគ្រាបន្ទាប់បានប្រមាណជាង ៨ខែ ខ្ពស់ជាងកម្រិត ៣ខែ ដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។

កំណើនសេដ្ឋកិច្ចត្រូវបានប៉ាន់ស្មានថាមានអត្រា ៧,១% នៅឆ្នាំ២០១៩ ដែលត្រូវបានរួមចំណែកជាចម្បងដោយកំណើនវិស័យសំណង់និងអចលនទ្រព្យ ទោះបីជាកំណើនវិស័យកម្មន្តសាលនិងទេសចរណ៍បានថមថយក៏ដោយ។ វិស័យសំណង់និងអចលនទ្រព្យបានបន្តរីកចម្រើនយ៉ាងឆាប់រហ័ស និងរួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ច ដែលគាំទ្រដោយមូលធនពីខាងក្រៅ ឥណទានក្នុងស្រុក និងកំណើនចំណូលរបស់ប្រជាជនកម្ពុជា។ ទន្ទឹមនេះ អត្រាអតិផរណាបន្តមានកម្រិតទាបជាមួយនឹងស្ថិរភាពអតិផរណាស្នូល គួបផ្សំនឹងការថយថ្លៃទំនិញពាក់ព័ន្ធនឹងប្រេងឥន្ធនៈ។ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាពល្អដោយមិនបានរងសម្ពាធណាមួយឡើយ។

ប្រព័ន្ធធនាគារកម្ពុជាដែលគ្របដណ្តប់ដោយធនាគារពាណិជ្ជ បន្តមានភាពធន់ ដែលឆ្លុះបញ្ចាំងដោយភាពគ្រប់គ្រាន់នៃដើមទុន សន្ទនីយភាព និងស្ថិរភាពនៃលទ្ធភាពស្វែងរកប្រាក់ចំណេញ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានរក្សាអនុបាតសាធនភាពខ្ពស់ ដោយជាមធ្យមមានកម្រិត ២៥% សម្រាប់គ្រឹះស្ថានធនាគារ ១៦,២% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៣៥,៩% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។ ចំពោះការគ្រប់គ្រងសន្ទនីយភាព គ្រឹះស្ថាន

ធនាគារនិងហិរញ្ញវត្ថុបន្តរក្សាអនុបាតគ្របខ័ណ្ឌសន្ទនីយភាព (LCR) ខ្ពស់ជាងកម្រិតអប្បបរមា (៩០%) ដោយអនុបាត LCR ជាមធ្យមមានកម្រិត ១៥៥,៧% សម្រាប់គ្រឹះស្ថានធនាគារ និង ១៧៨,១% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ លើសពីនេះ ប្រព័ន្ធធនាគារមានលទ្ធភាពស្វែងរកប្រាក់ចំណេញល្អប្រសើរ ដោយអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មជាមធ្យម ១,៩% សម្រាប់គ្រឹះស្ថានធនាគារ ២,៩% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ២,២% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។

ស្ថានភាពហិរញ្ញវត្ថុបន្តមានភាពអំណោយផល ខណៈកំណើនឥណទានក្នុងប្រព័ន្ធធនាគារនៅមានកម្រិតខ្ពស់។ គិតត្រឹមចុងឆ្នាំ២០១៩ ឥណទានក្នុងប្រព័ន្ធធនាគារមានកំណើន ២៥,៥% កើនឡើងពី ២៤,៥% នៅឆ្នាំ២០១៨ ដោយសារកំណើនឥណទានខ្ពស់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (៣២,៩%) និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (៣០,៦%) ខណៈដែលកំណើនឥណទានរបស់គ្រឹះស្ថានធនាគារមានកម្រិតថេរ។ ឥណទានរបស់គ្រឹះស្ថានធនាគារមានកំណើន ២៣,៦% ប្រហាក់ប្រហែលនឹងឆ្នាំ២០១៨។ កំណើនឥណទានបានរួមចំណែកជាចម្បងពីឥណទានទៅកាន់ការជួញដូរដុំនិងរាយ (៥,៨%) កម្ចីទិញផ្ទះ (៤,៥%) សកម្មភាពអចលនទ្រព្យ (៣,២%) ការប្រើប្រាស់ក្រុមគ្រួសារ (៣%) សំណង់ (៣%) កសិកម្ម (០,៤%) និងកម្មន្តសាល(០,២%)។

នាពេលខាងមុខ វិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជាអាចប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ ដោយសារតែការរីករាលដាលនៃវីរុសកូរ៉ូណា។ ការរីករាលដាលនៃវីរុសកូរ៉ូណាអាចជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចពិភពលោក ហើយសេដ្ឋកិច្ចកម្ពុជាក៏អាចទទួលរងផលប៉ះពាល់ផងដែរ ជាពិសេសវិស័យទេសចរណ៍ និងកម្មន្តសាល។ ទន្ទឹមនេះ ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចចិនអាចមានឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា ដែលមានទំនាក់ទំនងកាន់តែខ្លាំងជាមួយសេដ្ឋកិច្ចចិនក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ដោយឡែក គណៈកម្មការអឺរ៉ុបបានសម្រេចដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធអ្វីៗគ្រប់យ៉ាងលើកលែងសព្វាវុធ (EBA) ដែលនឹងតម្រូវឱ្យកម្ពុជាបង់ពន្ធប្រមាណ ២០% នៃការនាំចេញរបស់ខ្លួនទៅកាន់សហភាពអឺរ៉ុប។ ហេតុដូចនេះ ផលប៉ះពាល់ពីការដកផ្នែកខ្លះនៃ EBA ត្រូវបានព្យាករថានឹងមានកម្រិតទាបជាងការរំពឹងទុក។ ទោះយ៉ាងណា ប្រព័ន្ធធនាគារត្រូវបានរំពឹងថានឹងបន្តមានភាពធន់ ជាមួយនឹងភាពគ្រប់គ្រាន់នៃដើមទុន និងសន្ទនីយភាព។

# ១. ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

## ១.១ ស្ថានភាពនិងស្ថិរភាពវិស័យខាងក្រៅ

### ក- ស្ថានភាពវិស័យខាងក្រៅ

កំណើនសេដ្ឋកិច្ចពិភពលោកបានថយល្បឿននៅឆ្នាំ២០១៩ ដែលជាចម្បងបណ្តាលមកពីការកើនឡើងភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិកនិងចិន។ មូលនិធិរូបិយវត្ថុអន្តរជាតិបានទម្លាក់ការប៉ាន់ស្មានកំណើនសេដ្ឋកិច្ចពិភពលោកមកត្រឹម ២,៩% នៅឆ្នាំ២០១៩។ ការកើនឡើងភាពតានតឹងផ្នែកពាណិជ្ជកម្មបានធ្វើឱ្យសកម្មភាពពាណិជ្ជកម្មអន្តរជាតិថយចុះយ៉ាងខ្លាំង ដែលបណ្តាលឱ្យកំណើនសេដ្ឋកិច្ចថមថយទាំងនៅប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍។ ទន្ទឹមនេះ សេដ្ឋកិច្ចបណ្តាប្រទេសជាច្រើននៅក្នុងតំបន់ក៏មានកំណើនយឺតផងដែរ។ សម្រាប់ឆ្នាំ២០២០ មូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករថា កំណើនសេដ្ឋកិច្ចពិភពលោកអាចនឹងធ្លាក់ចុះក្នុងកម្រិតអវិជ្ជមាន ដោយសារការរីករាលដាលនៃវីរុសកូរ៉ូណា។ ចំណែកឯអត្រាអតិផរណានៅប្រទេសភាគច្រើនបន្តស្ថិតក្នុងកម្រិតទាប ដោយសារការថមថយសកម្មភាពសេដ្ឋកិច្ច និងការធ្លាក់ថ្លៃប្រេង។

ស្ថានភាពហិរញ្ញវត្ថុពិភពលោកនៅឆ្នាំ២០១៩ មានភាពធូរស្រាល ដោយធនាគារកណ្តាលភាគច្រើនបានអនុវត្តគោលនយោបាយរូបិយវត្ថុរិត្តបន្តឹង... 

ស្ថានភាពហិរញ្ញវត្ថុពិភពលោកនៅឆ្នាំ២០១៩ មានភាពធូរស្រាល ដោយធនាគារកណ្តាលភាគច្រើនបានអនុវត្តគោលនយោបាយរូបិយវត្ថុវិត្ថារកម្ម។ នៅឆ្នាំ២០១៩ ធនាគារកណ្តាលអាមេរិកបានទម្លាក់អត្រាការប្រាក់គោលចំនួន ៣ដង ឬ ០,៧៥% ស្របពេលដែលធនាគារកណ្តាលអឺរ៉ុបបានទម្លាក់អត្រាការប្រាក់គោលលើប្រាក់បញ្ញើបន្ថែមទៀត។ លើសពីនេះ ធនាគារកណ្តាលភាគច្រើននៅក្នុងតំបន់ ដូចជា ធនាគារកណ្តាលចិន ឥណ្ឌា ឥណ្ឌូណេស៊ី កូរ៉េ ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាមក៏បានបន្ទាបអត្រាការប្រាក់គោលផងដែរ ដើម្បីជួយជំរុញកំណើនសេដ្ឋកិច្ច ក្នុងពេលដែលការរំពឹងទុកអតិផរណាមានកម្រិតទាប។ ដើម្បីគាំទ្រដល់ការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចចេញពីការរីករាលដាលនៃវីរុសកូរ៉ូណា ស្ថានភាពហិរញ្ញវត្ថុពិភពលោកត្រូវបានរំពឹងថាបន្តបន្ធូរបន្ថយបន្ថែមទៀតក្នុងរយៈពេលខ្លីនិងមធ្យម។

### ខ- ស្ថិតិជញ្ជីងទូទាត់

#### - ពាណិជ្ជកម្ម

ក្នុងស្ថានភាពដែលកំណើនសេដ្ឋកិច្ចពិភពលោកបានថយល្បឿននៅឆ្នាំ២០១៩ ការនាំចេញរបស់កម្ពុជាមានកំណើនថមថយបន្តិច ខណៈដែលជញ្ជីងពាណិជ្ជកម្មបន្តមានឱនភាព ដោយសារការនាំចូលវត្ថុធាតុដើមមានការកើនឡើងខ្ពស់ ជាពិសេសការនាំចូលសម្ភារសំណង់ និងប្រេងឥន្ធនៈ។ ការនាំចេញទំនិញបានកើនឡើង ១២,៧% នៅឆ្នាំ២០១៩ ធៀបនឹងកំណើន ១៥,៥% នៅឆ្នាំ២០១៨ ប៉ុន្តែត្រូវបានធ្វើពិពិធកម្មជាបន្តបន្ទាប់ ដែលជំរុញជាចម្បងដោយផលិតផលកាត់ដេរសម្លៀកបំពាក់ ស្បែកជើង គ្រឿងអេឡិចត្រូនិក និងគ្រឿងបន្លាស់យានយន្ត។ ដៃគូពាណិជ្ជកម្មសំខាន់ៗសម្រាប់

ការនាំចេញរួមមាន សហរដ្ឋអាមេរិក (៣១% នៃការនាំចេញសរុប) សហភាពអឺរ៉ុប (២៦%) ជប៉ុន (៨%) ចិន (៧%) និងអង់គ្លេស (៧%)។ គួរកត់សម្គាល់ថា ការនាំចេញទៅសហរដ្ឋអាមេរិកបានកើនឡើងខ្ពស់ ជាពិសេសទំនិញសម្រាប់ធ្វើដំណើរ ដោយសារការទទួលបានប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP)។ ទន្ទឹមនេះ ការនាំចូលទំនិញបានកើនឡើង ១៨,៦% ទាបជាងកំណើននៅឆ្នាំ២០១៨ (២១,៣%) ដោយការនាំចូលយានយន្ត ប្រេងឥន្ធនៈ និងសម្ភារសំណង់បានកើនឡើងខ្ពស់ ខណៈការនាំចូលវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរមានកំណើនតិចជាងមុន។ ប្រទេសកម្ពុជានាំចូលទំនិញភាគច្រើនពីបណ្ដាប្រទេសក្នុងតំបន់ ដែលក្នុងនោះប្រទេសចិនមានសមាមាត្រប្រមាណ ៤៣% នៃការនាំចូលសរុប បន្ទាប់មកថៃ (១៦%) វៀតណាម (១៤%) ជប៉ុន (៥%) និងកូរ៉េ (៣%)។ ក្រាហ្វ ១ បង្ហាញពីសមតុល្យពាណិជ្ជកម្មទំនិញតាមប្រភេទនីមួយៗ។

**ក្រាហ្វ ១ ៖ ការនាំចេញ ការនាំចូល និងសមតុល្យពាណិជ្ជកម្មទំនិញ**

(ត្រីមាសទី១ ឆ្នាំ២០១៥ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព ៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## - វិស័យទេសចរណ៍

កំណើនវិស័យទេសចរណ៍បានថមថយល្បឿន ជាចម្បងដោយសារការថយចុះនៃកំណើនភ្ញៀវទេសចរចិន។ នៅឆ្នាំ២០១៩នេះ ភ្ញៀវទេសចរអន្តរជាតិបានកើនឡើងដល់ ៦,៦ លាននាក់ ដែលមានកំណើន ៦,៦% ធៀបនឹង ១០,៧% នៅឆ្នាំ២០១៨ ក្នុងនោះភ្ញៀវទេសចរមកពីប្រទេសចិន[១]មានចំនួន ២,៥ លាននាក់។ កំណើនរបស់ភ្ញៀវទេសចរអន្តរជាតិមានភាពល្អប្រសើរនៅឆមាសទី១ ឆ្នាំ២០១៩

[១] រួមបញ្ចូលទាំងហុងកុង ម៉ាកាវ និងតៃវ៉ាន់។

ប៉ុន្តែបានចាប់ផ្តើមថយចុះនៅឆមាសទី២ (ក្រាហ្វ ២) បន្ទាប់ពីរាជរដ្ឋាភិបាលបានប្រកាសពីការហាមឃាត់សកម្មភាពល្បែងភ្នាល់តាមប្រព័ន្ធអនឡាញ កាលពីខែសីហា។ សមាមាត្រនៃភ្ញៀវទេសចរអន្តរជាតិដែលមកកម្ពុជាក្នុងគោលបំណងធុរកិច្ច បានកើនឡើងទ្វេដងធៀបនឹងឆ្នាំមុន ខណៈសមាមាត្រនៃភ្ញៀវទេសចរអន្តរជាតិដែលមកក្នុងគោលបំណងកម្សាន្តបានថយចុះបន្តិច។ ប៉ុន្តែ នៅឆមាសទី២ សមាមាត្រនៃភ្ញៀវទេសចរអន្តរជាតិដែលមកកម្ពុជាក្នុងគោលបំណងធុរកិច្ចបានធ្លាក់ចុះ ស្របតាមនិន្នាការថយចុះនៃចំនួនភ្ញៀវទេសចរចិន។ គួរកត់សម្គាល់ថា ទោះបីជាមានការថយចុះកំណើនពី ៦២,១% នៅឆ្នាំ២០១៨ មកត្រឹម ១៥,៨% នៅឆ្នាំ២០១៩ ភ្ញៀវទេសចរចិននៅតែមានសមាមាត្រជាងមួយភាគបី (ក្រាហ្វ ៣) ដែលបង្ហាញថាវិស័យទេសចរណ៍ពឹងផ្អែកខ្លាំងទៅលើភ្ញៀវទេសចរចិន។

**ក្រាហ្វ ២ ៖ កំណើនភ្ញៀវទេសចរអន្តរជាតិ និងគោលដៅនៃការធ្វើដំណើរ**

(ជាភាគរយ, ខែធ្នូ ឆ្នាំ២០១៤ - ខែធ្នូ ឆ្នាំ២០១៩)




**ក្រាហ្វ ៣ ៖ សមាមាត្រនៃភ្ញៀវទេសចរអន្តរជាតិ**

(ជាភាគរយ, ឆ្នាំ២០១៨ និងឆ្នាំ២០១៩)




ប្រភព៖ ក្រសួងទេសចរណ៍ និងនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ

- **ប្រាក់បង្ញើរបស់ពលករ**

ប្រាក់បង្ញើរបស់ពលករបានកើនឡើងដល់ ១,៥ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ២០១៩។ ទោះយ៉ាងណា អត្រាកំណើនបានថយចុះពី ១០,៨% នៅឆ្នាំ២០១៨ មកត្រឹម ៦,៥% ដោយសារការធ្លាក់ចុះប្រាក់បង្ញើរបស់ពលករពីប្រទេសកូរ៉េ និងការថយល្បឿននៃប្រាក់បង្ញើរបស់ពលករពីប្រទេសថៃ (ក្រាហ្វ ៤)។ នៅឆ្នាំ២០១៩នេះ ប្រាក់បង្ញើរបស់ពលករពីប្រទេសជប៉ុនមានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ដល់ ៦៨,៦%។ ប្រទេសថៃនិងកូរ៉េនៅតែជាប្រភពនៃប្រាក់បង្ញើរបស់ពលករច្រើនជាងគេ ដែលមានសមាមាត្រ ៦៨,៥% និង ១៩,១% រៀងគ្នា បន្ទាប់មកគឺ ប្រទេសជប៉ុន ៥,២% និងប្រទេសម៉ាឡេស៊ី ២,៤% (ក្រាហ្វ ៥)។

**ក្រាហ្វ ៤ ៖ ប្រាក់បញ្ញើរបស់ពលករតាមប្រទេស**

(ជាលានដុល្លារអាមេរិក, ត្រីមាសទី១ ឆ្នាំ២០១៣-ត្រីមាសទី៤ ឆ្នាំ២០១៩)




**ក្រាហ្វ ៥ ៖ សមាមាត្រនៃប្រាក់បញ្ញើរបស់ពលករតាមប្រទេស**

(ជាភាគរយ, ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- **គណនីហិរញ្ញវត្ថុ**

លំហូរវិនិយោគផ្ទាល់បរទេស (FDI) បន្តមានភាពរឹងមាំ ដែលគ្រប់គ្រាន់សម្រាប់ផាត់ទាត់ដល់ឱនភាពគណនីចរន្ត។ លំហូរវិនិយោគផ្ទាល់បរទេសសរុបមានចំនួន ៣,៧ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៩ (កើនឡើង ១៥,២%) ដោយភាគច្រើនទៅកាន់វិស័យហិរញ្ញវត្ថុ សំណង់និងអចលនទ្រព្យ និងវិស័យកម្មន្តសាល។ លំហូរវិនិយោគផ្ទាល់បរទេសទៅកាន់វិស័យហិរញ្ញវត្ថុ ដែលមានសមាមាត្រប្រមាណមួយភាគបីនៃវិនិយោគផ្ទាល់បរទេសសរុប បានកើនឡើង ១៥,៨% នៅឆ្នាំ២០១៩ ខ្ពស់ជាងកំណើន ១១,១% នៅឆ្នាំ២០១៨។ ទន្ទឹមនេះ លំហូរវិនិយោគផ្ទាល់បរទេសទៅកាន់វិស័យសំណង់និងអចលនទ្រព្យ ដែលមានសមាមាត្រ ១៨,៦% នៃវិនិយោគផ្ទាល់បរទេសសរុប បានកើនឡើង ១៣,៧% និងទៅកាន់វិស័យកម្មន្តសាល ដែលមានសមាមាត្រ ១៧,១% មានកំណើន ៥០,១% ដែលបង្ហាញពីភាពទាក់ទាញនៃវិស័យទាំងនេះដល់វិនិយោគិនបរទេស (ក្រាហ្វ ៦)។

**ក្រាហ្វ ៦ ៖ លំហូរវិនិយោគផ្ទាល់បរទេសតាមវិស័យ**

(ត្រីមាសទី១ ឆ្នាំ២០១៣ - ត្រីមាសទី៤ ឆ្នាំ២០១៩)




**ក្រាហ្វ ៧ ៖ លំហូរវិនិយោគផ្ទាល់បរទេសតាមប្រទេស**

(ជាភាគរយ, ឆ្នាំ២០១៩)




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងធនាគារជាតិនៃកម្ពុជា

ប្រទេសចិនជាប្រភពចម្បងនៃលំហូរវិនិយោគផ្ទាល់បរទេសមកកម្ពុជា។ នៅឆ្នាំ២០១៩ លំហូរវិនិយោគផ្ទាល់បរទេសពីប្រទេសចិនមានសមាមាត្រ ៤៧% នៃវិនិយោគផ្ទាល់បរទេសសរុប បន្ទាប់មកគឺប្រទេសសិង្ហបុរី (៧,១%) កូរ៉េ (៦,៧%) វៀតណាម (៥%) ជប៉ុន (៤,៨%) អង់គ្លេស (៤,៦%) និង ម៉ាឡេស៊ី (៤,៣%) (ក្រាហ្វ ៧)។

បំណុលក្រៅប្រទេសដុល[២]បានកើនឡើង ដោយសារកំណើនលឿននៃការខ្ចីបរទេសរបស់គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ គិតត្រឹមដំណាច់ឆ្នាំ២០១៩នេះ បំណុលក្រៅប្រទេសដុលបានកើនឡើង ១៥,៨% ដល់ ១៥ ប៊ីលានដុល្លារអាមេរិក (៥៦,៣% នៃផ.ស.ស.) ពី ១៣ ប៊ីលានដុល្លារអាមេរិក (៥៤,៧% នៃផ.ស.ស.) នៅឆ្នាំមុន ដោយសារការកើនឡើងការខ្ចីរបស់គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ២៨,១%។ ការខ្ចីបរទេសរបស់គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធៀបនឹងផ.ស.ស. បានកើនពី ៤% នៅឆ្នាំ២០១០ ដល់ ២៥% នៅឆ្នាំ២០១៨ និងបានកើនឡើងដល់ ២៨,១% នៅឆ្នាំ២០១៩ (ក្រាហ្វ ៨)។ ដោយឡែក បំណុលសាធារណៈក្រៅប្រទេសធៀបនឹងផ.ស.ស. មានភាពប្រសើរឡើង ដោយបានថយចុះពី ២៩% នៅឆ្នាំ២០១៨ មក ២៧,៩% នៅឆ្នាំ២០១៩។ ទន្ទឹមនេះ បំណុលពីប្រទេសចិនមានសមាមាត្រប្រមាណ ៧៤% នៃបំណុលទ្វេភាគីសរុប និង ៤៨% នៃបំណុលសាធារណៈក្រៅប្រទេសសរុប (ក្រាហ្វ ៩)។

**ក្រាហ្វ ៨ ៖ សមាសធាតុនៃបំណុលក្រៅប្រទេសដុល**
(ជាភាគរយនៃផ.ស.ស., ឆ្នាំ២០១០ - ឆ្នាំ២០១៩)




**ក្រាហ្វ ៩ ៖ សមាសធាតុនៃបំណុលសាធារណៈក្រៅប្រទេស**
(ជាភាគរយ, ឆ្នាំ២០០៥ - ឆ្នាំ២០១៩)




ប្រភព ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា

[២] បំណុលក្រៅប្រទេសដុលរាប់បញ្ចូលបំណុលក្រៅប្រទេសរបស់រដ្ឋាភិបាល ធនាគារកណ្តាល និងគ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

## គ- អត្រាប្តូរប្រាក់ និងស្ថិរភាពវិស័យខាងក្រៅ

អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាព ដោយមិនបានប្រឈមនឹងសម្ពាធគួរឱ្យព្រួយបារម្ភឡើយ ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតប្រក្រតីនៃសូចនាករសម្ពាធទីផ្សារប្តូរប្រាក់ (EMP)[៣] (ក្រាហ្វ ១០)។ អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាម (NEER) និងអត្រាប្តូរប្រាក់ប្រសិទ្ធភាពពិត (REER) បានឡើងថ្លៃបន្តិច ធៀបនឹងឆ្នាំ២០១៨ ដែលមួយផ្នែកដោយសារប្រាក់រៀលឡើងថ្លៃធៀបនឹងប្រាក់យ៉ន់ចិន។ ទោះយ៉ាងណា អត្រា REER និង NEER ហាក់បានថយថ្លៃនៅឆមាសទី២ ឆ្នាំ២០១៩ ស្របតាមនិន្នាការនៃការឡើងថ្លៃនៃប្រាក់យ៉ន់ចិន (ក្រាហ្វ ១១)។

**ក្រាហ្វ ១០ ៖ សម្ពាធទីផ្សារប្តូរប្រាក់ (EMP)**
(ខែធ្នូ ឆ្នាំ២០១២ - ខែធ្នូ ឆ្នាំ២០១៩)




**ក្រាហ្វ ១១ ៖ អត្រាប្តូរប្រាក់ទ្វេភាគី និងអត្រាប្តូរប្រាក់ប្រសិទ្ធភាព**
(សន្ទស្សន៍ ឆ្នាំ២០១៥ = ១០០, ខែធ្នូ ឆ្នាំ២០១៤ - ខែធ្នូ ឆ្នាំ២០១៩)




ប្រភព ៖ ការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

ទុនបម្រុងអន្តរជាតិត្រូវបានគរពូនក្នុងកម្រិតខ្ពស់ ដែលបង្ហាញពីភាពរឹងមាំនិងជាទ្រនាប់ការពារហានិភ័យនានា។ ទុនបម្រុងអន្តរជាតិសរុបមានចំនួន ១៨,៨ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៩ (ក្រាហ្វ ១២) ដែលអាចធានាការនាំចូលទំនិញនិងសេវាគ្រាបន្ទាប់បានប្រមាណ ៨ខែ ខ្ពស់ជាងកម្រិតអប្បបរមាចំនួន ៣ខែ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ អនុបាតទុនបម្រុងអន្តរជាតិធៀបនឹងរូបិយវត្ថុទូទៅមានកម្រិត ៧៣,៣% ដែលលើសពីអត្រាគោលត្រឹម ២០%។ លើសពីនេះ អនុបាតទុនបម្រុងអន្តរជាតិធៀបនឹងផ.ស.ស. មានកម្រិត ៦៩,៨% និងធៀបជាមួយនឹងប្រាក់បញ្ញើជារូបិយប័ណ្ណមានអត្រា ៨៨,៧%។ ទោះយ៉ាងណា នៅក្នុងបរិការណ៍នៃសេដ្ឋកិច្ចដែលមានដុល្លារូបនីយកម្មខ្ពស់ និងរបបអត្រាប្តូរប្រាក់មានស្ថិរភាព កម្ពុជាត្រូវគរពូនទុនបម្រុងអន្តរជាតិបន្ថែមទៀត ដើម្បីជាទ្រនាប់ការពារហានិភ័យ ក្នុងគោលដៅរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

[៣] វិធីសាស្ត្រគណនាត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ។

**ក្រាហ្វ ១២ ៖ សូចនាករភាពគ្រប់គ្រាន់នៃទុនបម្រុងអន្តរជាតិ**

(ត្រីមាសទី១ ឆ្នាំ២០១៤ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ១.២ ស្ថានភាពនិងស្ថិរភាពសេដ្ឋកិច្ចកម្ពុជា

### ក- កំណើនសេដ្ឋកិច្ច និងអតិផរណា

សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថាមានកំណើន ៧,១% នៅឆ្នាំ២០១៩ ធៀបនឹងកំណើន ៧,៥% នៅឆ្នាំ២០១៨ ដែលគាំទ្រជាចម្បងដោយការកើនឡើងនៃវិស័យសំណង់និងអចលនទ្រព្យ ខណៈវិស័យកម្មន្តសាលនិងទេសចរណ៍មានកំណើនយឺត (ក្រាហ្វ ១៣)។ វិស័យកម្មន្តសាលមានកំណើនទាបជាងឆ្នាំមុនបន្តិច ដែលជាចម្បងដោយសារការថមថយកំណើនការនាំចេញសម្លៀកបំពាក់ និងស្បែកជើង ខណៈការនាំចូលវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរបានថមថយគួរឱ្យកត់សម្គាល់។ ទោះយ៉ាងណា ជំនឿទុកចិត្តរបស់វិនិយោគិនក្នុងវិស័យនេះមានភាពរឹងមាំ ដោយសារការកើនឡើងយ៉ាងឆាប់រហ័សនៃលំហូរវិនិយោគផ្ទាល់បរទេស ស្របពេលដែលចំនួនរោងចក្របានកើនឡើង។ ចំពោះវិស័យពាក់ព័ន្ធនឹងទេសចរណ៍ ផ្នែកសណ្ឋាគារនិងភោជនីយដ្ឋានបានថយល្បឿនក្នុងឆ្នាំ២០១៩ ស្របតាមការថមថយនៃកំណើនភ្ញៀវទេសចរអន្តរជាតិ ប៉ុន្តែសកម្មភាពដឹកជញ្ជូនបានកើនឡើងខ្ពស់។ ទន្ទឹមនេះ វិស័យសំណង់ទទួលបានកំណើនល្អ ជាមួយនឹងការកើនឡើងយ៉ាងលឿននៃចំនួនគម្រោងសំណង់ (កើន ៤៥,៥%) ការនាំចូលសម្ភារសំណង់ (កើន ៤៥,៦%) និងលំហូរវិនិយោគផ្ទាល់បរទេស (កើន ១៣,៧%)។ លើសពីនេះ ឥណទានធនាគារទៅកាន់វិស័យសំណង់និងអចលនទ្រព្យ បានកើនឡើង ៣៧,២% នៅឆ្នាំ២០១៩ (សមាមាត្រ ១៧,៨% នៃឥណទានសរុប)។ ដោយឡែក ទិន្នផលនៃវិស័យកសិកម្មបានធ្លាក់ចុះ -០,៥% នៅឆ្នាំ២០១៩ ដែលមួយផ្នែកដោយសារបញ្ហាអាកាសធាតុមិនអំណោយផល។ គួរកត់សម្គាល់ថា សមាមាត្រវិស័យកសិកម្មមាននិន្នាការថយចុះជាលំដាប់ពីប្រមាណ ២៨% នៅឆ្នាំ២០០៩ មកត្រឹម ១៦,៧% នៅឆ្នាំ២០១៩ (ក្រាហ្វ ១៤)។

**ក្រាហ្វ ១៣ ៖ ការរួមចំណែកក្នុងកំណើនផ.ស.ស.**

(ជាភាគរយ, ឆ្នាំ២០០៩ - ឆ្នាំ២០១៩ប៉ាន់ស្មាន)




**ក្រាហ្វ ១៤ ៖ សមាមាត្រនៃផ.ស.ស តាមវិស័យ**

(ជាភាគរយ, ឆ្នាំ២០០៩ - ឆ្នាំ២០១៩ប៉ាន់ស្មាន)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

ស្ថិរភាពអតិផរណាស្នូល និងការធ្លាក់ចុះនៃតម្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ បានរួមចំណែកធ្វើឱ្យអត្រាអតិផរណាមានកម្រិតទាបនៅឆ្នាំ២០១៩។ អត្រាអតិផរណាជាមធ្យមមានកម្រិត ១,៩% ទាបជាង ២,៥% នៅឆ្នាំ២០១៨ ប៉ុន្តែ នៅខែធ្នូ អតិផរណាបានកើនឡើងដល់ ៣,១% ជាចម្បងដោយសារតែការកើនឡើងនៃថ្លៃត្រី បន្លែ និងប្រេងសាំង។ ដូចបានបង្ហាញក្នុងក្រាហ្វ ១៥ ចំពោះប្រទេសដៃគូសំខាន់ៗដែលកម្ពុជានាំចូលទំនិញ អត្រាអតិផរណាមាននិន្នាការកើនឡើងនៅចុងឆ្នាំ។ នៅប្រទេសថៃ អតិផរណាមានស្ថិរភាព ខណៈពេលដែលអតិផរណារបស់ប្រទេសចិនបានកើនឡើងដល់ ៤,៥% នៅខែធ្នូ ឆ្នាំ២០១៩ ដែលបណ្តាលមកពីការកើនឡើងខ្លាំងនៃថ្លៃសាច់ជ្រូក ដោយសារការអូសបន្លាយនៃការរីករាលដាលនៃជំងឺគ្រុនផ្តាសាយជ្រូក។ ចំណែកឯអតិផរណានៅប្រទេសវៀតណាមបានកើនឡើងដល់ ៥,២% ដោយសារការឡើងថ្លៃផ្ទះនិងសម្ភារសំណង់។ គួរកត់សម្គាល់ថា ថ្លៃប្រេងនៅពិភពលោកបានថយចុះមកត្រឹម ៦៤ ដុល្លារអាមេរិកក្នុងមួយបារ៉ែល ធៀបនឹង ៧១ ដុល្លារអាមេរិកក្នុងមួយបារ៉ែល នៅឆ្នាំ២០១៨ ដែលការណ៍នេះបានធ្វើឱ្យថ្លៃដឹកជញ្ជូនបានធ្លាក់ចុះ (ក្រាហ្វ ១៦)។

**ក្រាហ្វ ១៥ ៖ អត្រាអតិផរណាកម្ពុជានិងប្រទេសដៃគូនាំចូលសំខាន់**

(ជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៦ - ខែធ្នូ ឆ្នាំ២០១៩)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និង Trading Economics

**ក្រាហ្វ ១៦ ៖ ការរួមចំណែកក្នុងអតិផរណារួម**

(ជាភាគរយ, ខែមករា ឆ្នាំ២០១៦ - ខែធ្នូ ឆ្នាំ២០១៩)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

## ខ- វិស័យរូបិយវត្ថុ

ការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន របស់ធនាគារជាតិនៃកម្ពុជា ក្នុងអំឡុងពេលពីរទសវត្សរ៍ចុងក្រោយនេះ បានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់។ ឧបករណ៍គោលនយោបាយរូបិយវត្ថុសំខាន់ៗ ដែលត្រូវបានប្រើប្រាស់ដើម្បីរក្សាស្ថិរភាពនេះ គឺការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ និងការកំណត់អត្រាប្រាក់បម្រុងកាតព្វកិច្ច។

ធនាគារជាតិនៃកម្ពុជាបានអនុវត្តរបបអត្រាប្តូរប្រាក់មានស្ថិរភាព តាមរយៈការអនុញ្ញាតឱ្យអត្រាប្តូរប្រាក់ប្រែប្រួលទៅតាមទីផ្សារ ប៉ុន្តែបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដើម្បីគ្រប់គ្រងនិងរក្សាស្ថិរភាពអត្រាប្តូរប្រាក់ទៅតាមគោលដៅដែលបានកំណត់ទុក។ ក្រៅពីនេះ អត្រាប្រាក់បម្រុងកាតព្វកិច្ចជាឧបករណ៍គោលនយោបាយរូបិយវត្ថុមួយទៀត ដែលត្រូវបានប្រើដើម្បីគ្រប់គ្រងល្បឿននៃកំណើនឥណទាន ដែលអាចជះឥទ្ធិពលលើអត្រាអតិផរណា ប៉ុន្តែឧបករណ៍នេះមិនត្រូវបានប្រើប្រាស់ជាប្រចាំនោះទេ។ គួរកត់សម្គាល់ថា អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានកំណត់ខុសគ្នាសម្រាប់រូបិយប័ណ្ណបរទេស (១២,៥%) និងរូបិយវត្ថុជាតិ (៨%) ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀល។[៤]

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុថ្មីៗបន្ថែមទៀត ដើម្បីគ្រប់គ្រងសន្ទនីយភាពក្នុងប្រព័ន្ធធនាគារឱ្យកាន់តែមានប្រសិទ្ធភាព។ នៅឆ្នាំ២០១៣ មូលបត្រអាចជួញដូរបាន (NCD) ជាប្រាក់រៀលនិងដុល្លារអាមេរិក ត្រូវបានចេញផ្សាយដើម្បីជំរុញកម្ចីអន្តរធនាគារប្រកបដោយសុវត្ថិភាព។ បន្ទាប់មក នៅឆ្នាំ២០១៦ ឧបករណ៍ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ការ

[៤] ឆ្លើយតបនឹងផលប៉ះពាល់ពីជំងឺកូវីដ១៩ ធនាគារជាតិនៃកម្ពុជាបានទម្លាក់អត្រាប្រាក់បម្រុងកាតព្វកិច្ចមកត្រឹម ៧% ជាបណ្តោះអាសន្ន ទាំងរូបិយវត្ថុជាតិនិងរូបិយប័ណ្ណបរទេស ចាប់ពីខែមេសាឆ្នាំ២០២០តទៅ។

ប្រើប្រាស់រូបិយវត្ថុជាតិ តាមរយៈការផ្គត់ផ្គង់សន្ទនីយភាពជាប្រាក់រៀលបន្ថែមទៀតទៅក្នុងប្រព័ន្ធធនាគារ។ ចាប់តាំងពីការចេញផ្សាយឧបករណ៍ទាំងនេះមក បរិមាណ NCD និង LPCO ដែលត្រូវបានផ្គត់ផ្គង់ បានកើនឡើងជាលំដាប់ (ក្រាហ្វ ១៧ និង ១៨)។

**ក្រាហ្វ ១៧ ៖ ចំនួននិងទំហំទឹកប្រាក់ NCD ជាប្រាក់រៀល (ឆ្វេង) និងជាដុល្លារអាមេរិក (ស្តាំ)**

(ខែធ្នូ ឆ្នាំ២០១៤ - ខែធ្នូ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៨ ៖ ទំហំទឹកប្រាក់ LPCO មិនទាន់ដល់ឥណប្រតិទាន**

(ជាប៊ីលានរៀល, ខែតុលា ឆ្នាំ២០១៦ - ខែធ្នូ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ដោយសារកម្រិតដុល្លារូបនីយកម្មខ្ពស់ ការអនុវត្តគោលនយោបាយរូបិយវត្ថុនៅមិនទាន់មានភាពពេញលេញ ដើម្បីជះឥទ្ធិពលទៅលើសកម្មភាពសេដ្ឋកិច្ចនៅឡើយទេ។ ដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ច បានដាក់កម្រិតដល់ការកំណត់អត្រាការប្រាក់គោលរបស់ធនាគារជាតិនៃកម្ពុជា ពីព្រោះអត្រាការប្រាក់ទីផ្សារត្រូវបានផ្សារភ្ជាប់ទៅនឹងគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលអាមេរិក ហើយដុល្លារូបនីយកម្មក៏បានដាក់កម្រិតផងដែរដល់ការដើរតួនាទីជាអ្នកឱ្យខ្ចីចុងក្រោយរបស់ធនាគារជាតិនៃកម្ពុជា នៅពេលសេដ្ឋកិច្ចជាតិជួបនឹងវិបត្តិ។

ដូច្នេះ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ ការលើកស្ទួយការប្រើប្រាស់រូបិយវត្ថុជាតិជាការចាំបាច់។ ធនាគារជាតិនៃកម្ពុជាបានតម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវមានសំពៀតឥណទានយ៉ាងតិច ១០% ជាប្រាក់រៀល ត្រឹមដំណាច់ឆ្នាំ២០១៩ និងបានជំរុញឱ្យសាធារណជនប្រើប្រាស់រូបិយវត្ថុជាតិឱ្យកាន់តែច្រើនជាងមុន តាមរយៈការអភិវឌ្ឍប្រព័ន្ធទូទាត់ដែលបង្កលក្ខណៈងាយស្រួលដល់ប្រតិបត្តិការជាប្រាក់រៀល, ការសាងសង់សារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ និងការរៀបចំយុទ្ធនាការជាច្រើនផ្សេងទៀត ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនពីសារៈសំខាន់នៃការប្រើប្រាស់ប្រាក់រៀល។

ទោះយ៉ាងណា ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលទាមទារការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិអាចត្រូវបានធ្វើឡើងតាមរយៈ៖ ការបង្កើនការបើកប្រាក់បៀវត្សរ៍ដល់និយោជិតជាប្រាក់រៀលក្នុងវិស័យឯកជន, ការដាក់តាំងថ្លៃទំនិញនិងសេវាជាប្រាក់រៀលតែមួយគត់, ការទូទាត់គ្រប់សេវាសាធារណៈទាំងអស់ជាប្រាក់រៀល ដូចជា ការបង់ថ្លៃសិក្សា សំបុត្រចូលទស្សនានៅតាមរមណីយដ្ឋានទេសចរណ៍ សេវាព្យាបាល និងសេវាធ្វើលិខិតឆ្លងដែនជាដើម។

## គ- វិស័យសារពើពន្ធ

ការប្រមូលចំណូលបានបន្តកើនឡើងជាបន្តបន្ទាប់ ដែលបានធ្វើឱ្យសមតុល្យសារពើពន្ធមានអតិរេកជាលើកដំបូង។ នៅឆ្នាំ២០១៩ សមតុល្យសារពើពន្ធមានអតិរេក ០,៣% នៃផ.ស.ស. ធៀបនឹងឱនភាព ០,៦% នៅឆ្នាំ២០១៨ (ក្រាហ្វ ១៩)។[៥] ការប្រមូលចំណូលបានកើនឡើង ២៩,១% ដែលបានធ្វើឱ្យចំណូលធៀបនឹងផ.ស.ស. កើនដល់ ២៣,៣% នៅឆ្នាំ២០១៩ ធៀបនឹង ១៩,៨% នៅឆ្នាំមុន។ កិច្ចខិតខំប្រឹងប្រែងនិងប្រសិទ្ធភាពនៃការអនុវត្តការប្រមូលចំណូល ក្រោមយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ២០១៤-២០១៨ ជាកត្តារួមចំណែកដ៏សំខាន់ក្នុងកំណើននេះ។ ជាក់ស្តែង អាករលើតម្លៃបន្ថែមនិងពន្ធគយ (៥៤,៣% នៃចំណូលសរុប) ពន្ធផ្ទាល់ (១៩,៨%) និងពន្ធពាណិជ្ជកម្មអន្តរជាតិលើការនាំចូល (១១,៤%) បានកើនឡើង ៣០,៤% ២៩,៧% និង ២២,៩% រៀងគ្នា ធៀបនឹងឆ្នាំមុន។

[៥] ទិន្នន័យត្រូវបានធ្វើបច្ចុប្បន្នភាពត្រឹមខែមីនា ឆ្នាំ២០២០ ហើយអាចនឹងត្រូវកែតម្រូវបន្ថែមទៀត ដោយសារទិន្នន័យចំណាយជាទូទៅអាចយឺតរហូតដល់ ៦ខែ ឬយូរជាងនេះ។

ចំណាយសរុបបានកើនឡើង ដោយសារការកើនឡើងនៃចំណាយមិនមែនបៀវត្សរ៍ និងចំណាយមូលធន។ ចំណាយសរុបមានសមាមាត្រប្រមាណ ២៣% នៃផ.ស.ស. ដោយបានកើនឡើង ២៣,៦% នៅឆ្នាំ២០១៩។ ចំណាយចរន្ត (៧០,១% នៃចំណាយសរុប) បានកើនឡើង ២៣,៨% ដែលភាគច្រើនជំរុញដោយចំណាយមិនមែនបៀវត្សរ៍ ៩៧,៥% និងចំណាយបៀវត្សរ៍ ៣,៩% ធៀបនឹងឆ្នាំ២០១៨។ គួរកត់សម្គាល់ថា ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ (២០១៤-២០១៨) ចំណាយបៀវត្សរ៍បានកើនឡើងជាង ២០% (កើនជិត ១% នៃផ.ស.ស. ក្នុងមួយឆ្នាំ)។ ទន្ទឹមនេះ ចំណាយមូលធនបានកើនឡើង២៣,២%ដែលគាំទ្រជាចម្បងដោយការកើនឡើងហិរញ្ញប្បទានពីបរទេសចំនួន ៣៣,៩%។

**ក្រាហ្វ ១៩ ៖ គណនីសារពើពន្ធ**

(ជាភាគរយនៃផ.ស.ស. ឆ្នាំ២០០៨ - ឆ្នាំ២០១៩)




ប្រភព ៖ អគ្គនាយកដ្ឋានរតនាគារជាតិ

បំណុលសាធារណៈស្ថិតនៅទាបដែលបង្ហាញពីកម្រិតហានិភ័យទាប។ គិតត្រឹមចុងឆ្នាំ២០១៩ បំណុលសាធារណៈមានចំនួន ៧,៦ ប៊ីលានដុល្លារអាមេរិក (២៨,៥% នៃផ.ស.ស.) ដែលបានកើនឡើង ៩,១%។ ការខ្ចីទ្វេភាគីមានសមាមាត្រ ៧១,៣% នៃបំណុលសាធារណៈសរុប ដែលក្នុងនោះបំណុលពីប្រទេសចិន ៤៧,១% ប្រទេសជប៉ុន ៥,៤% និងប្រទេសកូរ៉េ ៥% ហើយកម្ចីពហុភាគីមានសមាមាត្រ ២៨,៧%។ បំណុលតាមរូបិយប័ណ្ណសំខាន់ៗមានចំនួន ៣ (សមាមាត្រជាង ៨៥% នៃបំណុលសាធារណៈសរុប)៖ ប្រាក់ដុល្លារអាមេរិក (៤៣%) អេសដេអ៊ែរ (២៧%) និងប្រាក់យ៉ន់ចិន (១៦%) (ក្រាហ្វ ២០)។ ជារួម បំណុលសាធារណៈរបស់ប្រទេសកម្ពុជាបន្តមានចីរភាព ដោយអនុបាតបំណុលសាធារណៈធៀបនឹងផ.ស.ស. មានកម្រិតទាបជាង ៥០% នៃផ.ស.ស.។ ជាមួយគ្នានេះ ការវិភាគចីរភាពបំណុលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏បានបង្ហាញថា សូចនាករបំណុលគន្លឹះៗចំនួន ៥[៦] គឺសុទ្ធតែស្ថិតនៅទាបជាងកម្រិតអនុបាតគោលផងដែរ។

[៦] i/-អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈធៀបនឹងផ.ស.ស. ii/-អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹងផ.ស.ស. iii/-អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញ iv/-អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញ និង v/-អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេសធៀបនឹងចំណូលថវិកាជាតិ។

**ក្រាហ្វ ២០ ៖ បំណុលក្រៅប្រទេសបែងចែកតាមរូបិយប័ណ្ណ**

(ត្រីមាសទី១ ឆ្នាំ២០០៨ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព ៖ អគ្គនាយកដ្ឋានរតនាគារជាតិ

## ឃ- វិស័យសំណង់និងអចលនទ្រព្យ

វិស័យសំណង់និងអចលនទ្រព្យបានរីកចម្រើនយ៉ាងឆាប់រហ័ស ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និងបានក្លាយជាសសរស្តម្ភមួយក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ វិស័យសំណង់និងអចលនទ្រព្យបានរួមចំណែកប្រមាណមួយភាគបីក្នុងកំណើនសេដ្ឋកិច្ច ខណៈដែលចំណែកឥណទានធនាគារទៅកាន់វិស័យសំណង់និងអចលនទ្រព្យ បានកើនឡើងជាលំដាប់ពី ១៩% នៅឆ្នាំ២០១៥ ដល់ ២៩% នៅឆ្នាំ២០១៩ ជាមួយនឹងអត្រាកំណើនជាមធ្យម ៣៩% ក្នុងមួយឆ្នាំ។ ស្របពេលជាមួយគ្នានេះ ការផ្តល់កម្ចីដោយក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យក្រោមរូបភាពជាការបង់រំលស់ផ្ទាល់ដល់អ្នកទិញផ្ទះ ក៏ត្រូវបានប៉ាន់ស្មានថាបានកើនឡើងលឿនផងដែរ។ គួររំលេចថា ទិន្នន័យលើការផ្តល់កម្ចីរបស់ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យនៅពុំទាន់មាន ហើយទាមទារនូវកិច្ចសហការជិតស្និទ្ធរវាងអាជ្ញាធរពាក់ព័ន្ធ ដើម្បីធានាដល់ការអភិវឌ្ឍវិស័យសំណង់និងអចលនទ្រព្យប្រកបដោយចីរភាពនិងបរិយាបន្ន។ ធនាគារជាតិនៃកម្ពុជាបានបន្តតាមដានយ៉ាងយកចិត្តទុកដាក់លើការអភិវឌ្ឍវិស័យសំណង់និងអចលនទ្រព្យ និងហានិភ័យនានាដែលអាចប៉ះពាល់ដល់វិស័យធនាគារ។ ដោយមានការគាំទ្រពីជំនួយបច្ចេកទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបង្កើតសន្ទស្សន៍ថ្លៃលំនៅដ្ឋាន (RPPI) ផ្អែកលើព័ត៌មានពីកម្ចីទិញផ្ទះរបស់អតិថិជនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលរំពឹងថានឹងត្រូវបានផ្សព្វផ្សាយជាផ្លូវការនៅចុងឆ្នាំនេះ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានធ្វើការអង្កេតលើការកំណត់អនុបាតឥណទានធៀបនឹងទ្រព្យបញ្ចាំ (LTV) សម្រាប់ការផ្តល់កម្ចីទិញផ្ទះ ដើម្បីស្វែងយល់ពីការអនុវត្តនាពេលបច្ចុប្បន្នក្នុងចំណោមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

នៅឆ្នាំ២០១៩ ការវិនិយោគក្នុងវិស័យសំណង់ដែលទទួលបានការអនុម័ត បានកើនឡើងគួរឱ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនយ៉ាងឆាប់រហ័សនៃចំនួនគម្រោង ទំហំទឹកប្រាក់វិនិយោគ និងផ្ទៃដីសាងសង់សរុប។ យោងតាមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួនគម្រោងសាងសង់ដែលបានអនុម័តបានកើនឡើង ៥៥,៥% ដែលមាន ៥.៧៩៣ គម្រោង ទទួលបានការអនុម័តនៅឆ្នាំ២០១៩ ធៀបនឹង ៣.២៩៤ គម្រោងនៅឆ្នាំ២០១៨ (ក្រាហ្វ ២១)។ ដូចដែលបានបង្ហាញក្នុងក្រាហ្វ ២២ ការអនុម័តលើការវិនិយោគក្នុងវិស័យសំណង់បានកើនឡើង ៩៨,៤% នៅឆ្នាំ២០១៩ ពី ៥,៨ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៨ ដល់ ១១,៤ ប៊ីលានដុល្លារអាមេរិក។ ជាមួយគ្នានេះ ចំនួនគម្រោងលំនៅដ្ឋាន (ជាពិសេសបុរីនិងខុនដូ) និងគម្រោងពាណិជ្ជកម្ម មានសមាមាត្រធំជាងគេនៅក្នុងចំនួនគម្រោងដែលបានអនុម័តសរុប ដោយមានចំណែក ៨៣,១% និង ៧,៣% រៀងគ្នា។ ទំហំផ្ទៃដីសាងសង់សរុបបានកើនឡើង ៨៤,៦% ដល់ ២៣,២ លានម៉ែត្រការ៉េ ក្នុងនោះគម្រោងលំនៅដ្ឋានដែលបានអនុម័តមានសមាមាត្រ ៤៦,៥% នៃផ្ទៃដីសាងសង់សរុប ហើយគម្រោងពាណិជ្ជកម្មមានសមាមាត្រ ៣១,៥% (ក្រាហ្វ ២៣)។ គួរកត់សម្គាល់ថា សមាមាត្រនៃគម្រោងឧស្សាហកម្មបានកើនឡើងគួរឱ្យកត់សម្គាល់ពី ៧% នៃផ្ទៃដីសាងសង់សរុបនៅឆ្នាំ២០១៨ ដល់ ១៥,៩% នៅឆ្នាំ២០១៩ ដែលបង្ហាញពីទំនុកចិត្តរបស់វិនិយោគិនទៅលើសេដ្ឋកិច្ចកម្ពុជា។

**ក្រាហ្វ ២១ ៖ ចំនួននិងប្រភេទគម្រោងសាងសង់**
(ឆ្នាំ២០១៥ - ឆ្នាំ២០១៩)




**ក្រាហ្វ ២២ ៖ តម្លៃនៃគម្រោងសាងសង់ដែលបានអនុម័ត**
(ឆ្នាំ២០១៥ - ឆ្នាំ២០១៩)




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ក្រាហ្វ ២៣ ៖ សមាមាត្រនៃផ្ទៃដីសាងសង់តាមវិស័យ**
(ជាភាគរយ, ឆ្នាំ២០១៩)




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ក្រាហ្វ ២៤ ៖ ការនាំចូលសម្ភារសំណង់**
(ត្រីមាសទី១ ឆ្នាំ២០១៥ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ការនាំចូលសម្ភារនិងបរិក្ខារសំណង់បានបន្តកើនឡើងយ៉ាងឆាប់រហ័ស ស្របពេលដែលការផ្គត់ផ្គង់ស៊ីម៉ង់ត៍ក្នុងស្រុកក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ នៅឆ្នាំ២០១៩ ប្រទេសកម្ពុជាបាននាំចូលសម្ភារនិងបរិក្ខារសំណង់ចំនួន ២,៣ ប៊ីលានដុល្លារអាមេរិក រួមមាន ដែក ស៊ីម៉ង់ត៍ និងឧបករណ៍ផ្សេងៗទៀត ដោយបានកើនឡើង ៤៧,២% ធៀបនឹងឆ្នាំមុន (ក្រាហ្វ ២៤)។ ជាមួយគ្នានេះ ការផលិតស៊ីម៉ង់ត៍ក្នុងស្រុកមានចំនួន ៧,៩ លានតោន[៧] ដែលអនុញ្ញាតឱ្យប្រទេសកម្ពុជាកាត់បន្ថយបរិមាណការនាំចូលស៊ីម៉ង់ត៍សម្រាប់ផ្គត់ផ្គង់ដល់វិស័យសំណង់ដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស។

ស្របតាមការរីកចម្រើននៃវិស័យសំណង់ សូចនាករទីផ្សារមួយចំនួនក៏បានបង្ហាញពីការកើនឡើងផងដែរនៅឆ្នាំ២០១៩នេះ។ យោងតាមរបាយការណ៍របស់ CBRE[៨] តម្លៃដីនៅខណ្ឌធំៗក្នុងរាជធានីភ្នំពេញ បានកើនឡើងជាមធ្យម ១២%។ ការផ្គត់ផ្គង់ខុនដូនៅរាជធានីភ្នំពេញបានកើនឡើងប្រមាណ ២៧% ដល់ជាង ១៤០.០០០ យូនីត ខណៈដែលតម្លៃនៃប្រភេទខុនដូកម្រិតមធ្យម និងកម្រិតសមរម្យមានការកើនឡើងជាលំដាប់។ ក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ Knight Frank[៩] ក៏បានបង្ហាញថា ចំនួនផ្ទះដែលមាននៅក្នុងបុរីចំនួន ១៣១ នៅរាជធានីភ្នំពេញ បានកើនដល់ប្រមាណ ៥១.០០០ ខ្នង នៅឆមាសទី១ ឆ្នាំ២០១៩ ដែលបានកើនឡើង ១១% ធៀបនឹងចុងឆ្នាំ២០១៨។

[៧] យោងតាមការចុះផ្សាយរបស់សារព័ត៌មានខ្មែរថាមស៍ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០។

[៨] CBRE, របាយការណ៍ Market View Phnom Penh (ត្រីមាសទី៤ ឆ្នាំ២០១៩)។

[៩] Knight Frank, របាយការណ៍ Cambodia Real Estate Highlights (ឆមាសទី១ ឆ្នាំ២០១៩)។

# ២. ស្ថានភាពនិងការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុ

## ២.១ ទិដ្ឋភាពទូទៅ ស្ថានភាព និងការវាយតម្លៃប្រព័ន្ធធនាគារ

### ក- ទិដ្ឋភាពទូទៅប្រព័ន្ធធនាគារ

ប្រព័ន្ធធនាគារកម្ពុជា[១០] ដែលបច្ចុប្បន្នគ្របដណ្តប់ដោយធនាគារពាណិជ្ជ បន្តរក្សាបានភាពរឹងមាំទាំងផ្នែកដើមទុននិងសន្ទនីយភាព។ ការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យធនាគារត្រូវបានគាំទ្រជាចម្បងដោយស្ថិរភាពនយោបាយនិងសេដ្ឋកិច្ច ដែលអាចឱ្យប្រព័ន្ធធនាគារមានភាពទាក់ទាញការវិនិយោគកាន់តែច្រើន និងផ្តល់សេវាហិរញ្ញវត្ថុយ៉ាងសម្បូរបែប។ ទន្ទឹមនេះ ជំនឿទុកចិត្តមកលើប្រព័ន្ធធនាគារបានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កេណ្ឌប្រមូលប្រាក់សន្សំបានយ៉ាងច្រើនពីអ្នកដាក់ប្រាក់បញ្ញើ ដែលបានផ្តល់ជាសន្ទនីយភាពបន្ថែមដល់គ្រឹះស្ថានទាំងនោះ។

**ក្រាហ្វ ២៥ ៖ ប្រព័ន្ធធនាគារកម្ពុជា**

(ឆ្នាំ២០១៧ - ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២៦ ៖ ចំណែកទ្រព្យសកម្ម**

(ជាភាគរយ ត្រីមាសទី១ ឆ្នាំ២០១៣ - ត្រីមាសទី៤ ឆ្នាំ២០១៩)




**ក្រាហ្វ ២៧ ៖ ចំណែកឥណទាន**

(ជាភាគរយ ត្រីមាសទី១ ឆ្នាំ២០១៣ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[១០] នៅឆ្នាំ២០១៩ ប្រព័ន្ធធនាគារមាន៖ ធនាគារពាណិជ្ជ ៤៧ ធនាគារឯកទេស ១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៨២ (៦ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៧៦ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ២១ ក្រុមហ៊ុនភតិសន្យា ១៥ និង គ្រឹះស្ថានឥណទានជនបទ ២៤៥។

ដើម្បីរួមចំណែកគាំទ្រកំណើនសេដ្ឋកិច្ច គ្រឹះស្ថានធនាគារពាណិជ្ជ និងធនាគារឯកទេស បានផ្តល់ឥណទានទៅកាន់វិស័យសំខាន់ៗដូចជា ការជួញដូរដុំនិងរាយ សំណង់ និងអចលនទ្រព្យ។ ចំណែកឥណទានគ្រឹះស្ថានធនាគារទៅវិស័យ សំណង់ អចលនទ្រព្យ និងកម្ចីទិញផ្ទះ បានកើនឡើងដល់ ៩,៩% ៨,៨% និង ១១,៩% នៃឥណទានសរុប រៀងគ្នា ខណៈឥណទានធនាគារទៅវិស័យកម្មន្តសាល ដែលជាវិស័យចម្បងគាំទ្រការនាំចេញ បានធ្លាក់ចុះបន្តិចមក ៤,៦%។ ទន្ទឹមនេះ ការជួញដូរដុំ និងការជួញដូររាយបានថយចុះបន្តិចមក ១១,៥% និង ១៦,១% រៀងគ្នា។ (ក្រាហ្វ ២៨)

**ក្រាហ្វ ២៨ ៖ ចំណែកឥណទានគ្រឹះស្ថានធនាគារតាមវិស័យ**

(ជាភាគរយ ត្រីមាសទី១ ឆ្នាំ២០១៣ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បន្តរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលបានពង្រីកតួនាទីរបស់គ្រឹះស្ថានទាំងនេះក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងរួមចំណែកដល់ការអភិវឌ្ឍជនបទ។ ចំណែកទ្រព្យសកម្មនិងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានកើនឡើងបន្តិចម្តងៗដល់ ១៥% នៃទ្រព្យសកម្មសរុប និង ១៩,៣% នៃឥណទានសរុប រៀងគ្នា ដែលមានកំណើនប្រមាណ ១% ធៀបនឹងឆ្នាំ២០១៨។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានបង្កើនការផ្តល់សេវាហិរញ្ញវត្ថុ និងពង្រីកទំហំប្រតិបត្តិការជាបន្តបន្ទាប់ ដែលបានធ្វើឱ្យគ្រឹះស្ថានមួយចំនួនមានទំហំប្រហាក់ប្រហែលនឹងធនាគារពាណិជ្ជ។ ដោយឡែក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទោះបីជាចំនួនបានកើនឡើងច្រើនក្តី ក៏ប្រតិបត្តិការគ្រឹះស្ថានទាំងនេះនៅតែមានទំហំតូចក្នុងប្រព័ន្ធធនាគារ។ (ក្រាហ្វ ២៦ និង ២៧)

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បន្តផ្តល់ឥណទានមួយភាគធំទៅកាន់ក្រុមគ្រួសារ ខណៈសមាមាត្រឥណទានទៅកាន់វិស័យកសិកម្មកាន់តែរួមតូច។ ឥណទានទៅកាន់ក្រុមគ្រួសារមានចំណែកធំជាងគេក្នុងចំណោមវិស័យផ្សេងទៀត ក្នុងកម្រិតប្រមាណ ៣៣,៣% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៣៩,៨% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ខណៈឥណទានទៅកាន់វិស័យកសិកម្មបានថយចុះក្នុងរយៈពេលបីឆ្នាំចុងក្រោយពី ៣៦% នៅឆ្នាំ២០១៦ មក ២០,៨% នៅឆ្នាំ២០១៩ សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងពី ១៦,៦% មក ១០,២% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ (ក្រាហ្វ ២៩ និង ៣០)

**ក្រាហ្វ ២៩ ៖ ចំណែកឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើតាមវិស័យ**
(ជាភាគរយ ត្រីមាសទី១ ឆ្នាំ២០១៣ - ត្រីមាសទី៤ ឆ្នាំ២០១៩)




**ក្រាហ្វ ៣០ ៖ ចំណែកឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមវិស័យ**
(ជាភាគរយ ត្រីមាសទី១ ឆ្នាំ២០១៣ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ- លទ្ធភាពស្វែងរកប្រាក់ចំណេញ

លទ្ធភាពស្វែងរកប្រាក់ចំណេញក្នុងប្រព័ន្ធធនាគារនៅឆ្នាំ២០១៩ បន្តមានស្ថិរភាពល្អ ដោយអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) របស់គ្រឹះស្ថានធនាគារមានកម្រិត ១,៩% គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ២,៩% និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ២,២% ស្របពេលដែលអនុបាតប្រាក់ចំណេញធៀបនឹងដើមទុន (ROE) មានកម្រិត ៩,៨% ១៧,៧% និង ៦,៣% រៀងគ្នា។ គួររំលេចថាក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ប្រាក់ចំណេញក្នុងប្រព័ន្ធធនាគារមាននិន្នាការថយចុះ ខណៈអនុបាតប្រសិទ្ធភាពការគ្រប់គ្រងចំណាយ (EFR) របស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានកម្រិតថេរ។ និន្នាការថយចុះនៃ ROA និង ROE បណ្ដាលមកពីការកើនឡើងការប្រកួតប្រជែង ការអនុវត្តតាមបទប្បញ្ញត្តិថ្មីៗដែលមានភាពតឹងរ៉ឹង និងការខាតបង់របស់គ្រឹះស្ថានមួយចំនួនតូចដែលភាគច្រើនជាគ្រឹះស្ថានទើបបង្កើតថ្មី។

**ក្រាហ្វ ៣១ ៖ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម**
(ជាភាគរយ ត្រីមាសទី២ ឆ្នាំ២០១៣ - ត្រីមាសទី៤ ឆ្នាំ២០១៩)




**ក្រាហ្វ ៣២ ៖ អនុបាតប្រាក់ចំណេញធៀបនឹងដើមទុន**
(ជាភាគរយ ត្រីមាសទី២ ឆ្នាំ២០១៣ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបន្តមានលទ្ធភាពស្វែងរកប្រាក់ចំណេញ ជាចម្បងដោយសារការគ្រប់គ្រងចំណាយប្រកបដោយប្រសិទ្ធភាព។ ROA និង ROE របស់គ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានស្ថិរភាព ស្របពេលដែលការគ្រប់គ្រងចំណាយរបស់គ្រឹះស្ថានត្រូវបានអនុវត្តល្អជាងមុន ដោយការថយចុះជាសន្សឹមៗនៃ EFR។ ជារួម លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពឹងផ្អែកជាចម្បងលើចំណូលពីការប្រាក់ឥណទានដែលមានកម្រិតប្រមាណ ៩៨% នៃចំណូលសរុប។ ដោយឡែក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅតែមាន ROA និង ROE ស្ថិតក្នុងកម្រិតទាប ព្រមទាំងមាន EFR ខ្ពស់ជាងគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដោយសារភាពខុសគ្នានៃទម្រង់ធុរកិច្ចដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពឹងផ្អែកទៅលើកម្ចីនិងដើមទុនជាប្រភពទុនចម្បង ជាជាងពឹងផ្អែកលើប្រាក់បញ្ញើ។

**ក្រាហ្វ ៣៣ ៖ អនុបាតប្រសិទ្ធភាពការគ្រប់គ្រងចំណាយ**

(ជាភាគរយ ត្រីមាសទី២ ឆ្នាំ២០១៣ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៤ ៖ រចនាសម្ព័ន្ធប្រាក់ចំណេញ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**

(ជាភាគរយ ឆ្នាំ២០១៣ - ឆ្នាំ២០១៩)




**ក្រាហ្វ ៣៥ ៖ រចនាសម្ព័ន្ធប្រាក់ចំណេញ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

(ជាភាគរយ ឆ្នាំ២០១៣ - ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## គ- ស្ថានភាពដើមទុន

ក្រាហ្វ ៣៦ ៖ អនុបាតសាធនភាព

(ជាភាគរយ ត្រីមាសទី២ ឆ្នាំ២០១៣ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រព័ន្ធធនាគាររក្សាបានកម្រិតអនុបាតសាធនភាព ជាមធ្យមខ្ពស់ជាងកម្រិតដែលតម្រូវឱ្យមានតាមបទប្បញ្ញត្តិ (១៥%)។ អនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារនៅចុងឆ្នាំ២០១៩ ជាមធ្យម មានកម្រិតខ្ពស់និងមានស្ថិរភាពប្រមាណ ២៤%។ សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អនុបាតសាធនភាពជាមធ្យម មានកម្រិតប្រមាណ ១៦,២% ខ្ពស់ជាងកម្រិតបទប្បញ្ញត្តិបន្តិច ខណៈអនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាមធ្យម បានថយចុះមក ៣៤,៩% ដែលក្នុងនោះអនុបាតរបស់គ្រឹះស្ថានមួយចំនួនមានកម្រិតទាបជាង ១៥%។

គួរបញ្ជាក់ថា អនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មិនអាចយកមកប្រៀបធៀបដើម្បីបង្ហាញពីស្ថានភាពដើមទុនរវាងគ្រឹះស្ថានទាំងបីប្រភេទបានទេ ដោយសារភាពខុសគ្នានៃបទប្បញ្ញត្តិនិងទម្រង់ធុរកិច្ចនៃប្រភេទគ្រឹះស្ថានទាំងបី។

## ឃ- ស្ថានភាពសន្ទនីយភាពនិងការផ្តល់ហិរញ្ញប្បទាន

ក្រាហ្វ ៣៧ ៖ អនុបាតក្របខ័ណ្ឌសន្ទនីយភាព

(ជាភាគរយ ត្រីមាសទី២ ឆ្នាំ២០១៣ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

គ្រឹះស្ថានធនាគារពាណិជ្ជជារួម អាចមានលទ្ធភាពធន់នឹងសម្ពាធសន្ទនីយភាពរយៈពេលខ្លី ដោយអនុបាតក្របខ័ណ្ឌសន្ទនីយភាពជាមធ្យមស្ថិតក្នុងកម្រិត ១៥៥,៧% ដែលខ្ពស់ជាងកម្រិតបទប្បញ្ញត្តិ (៩០%) ហើយប្រាក់បញ្ញើជាប្រភពទុនចម្បងរបស់គ្រឹះស្ថានធនាគារ។ ក្នុងរយៈពេលជាច្រើនឆ្នាំ គ្រឹះស្ថានធនាគារពាណិជ្ជបានបង្កើនសន្ទនីយភាពតាមរយៈប្រាក់បញ្ញើអតិថិជន ព្រមទាំងបានកាត់បន្ថយការពឹងផ្អែកលើកម្ចីពីក្រៅប្រទេស។ ក្នុងក្រាហ្វ ៣៧ របារពណ៌លឿងតំណាងអោយការគណនាអនុបាតសន្ទនីយភាពដោយប្រើប្រាស់វិធីសាស្រ្តចាស់ ដែលកំណត់

យកកម្រិត ៥០% ជាកម្រិតអប្បបរមា ហើយចាប់ពីឆ្នាំ២០១៦តទៅ អនុបាតគ្របខណ្ឌសន្ទនីយភាព ត្រូវបានប្រើប្រាស់សម្រាប់គណនាកម្រិតសន្ទនីយភាពក្នុងប្រព័ន្ធធនាគារ ដោយអនុលោមតាម ប្រកាសស្តីពី អនុបាតគ្របខណ្ឌសន្ទនីយភាព។ នៅឆ្នាំ២០១៩ អនុបាតគ្របខណ្ឌសន្ទនីយភាព អប្បបរមាមានកម្រិត ៩០% និងត្រូវដំឡើងដល់កម្រិត ១០០% នៅឆ្នាំ២០២០។

គិតត្រឹមចុងឆ្នាំនេះ គ្រឹះស្ថានធនាគារទទួលបានប្រភពទុនពី៖ ប្រាក់បញ្ញើ ៦៩% និងមូលនិធិកម្ចី ១១% នៃប្រភពទុនសរុប ក្នុងនោះ ៦០% ជាកម្ចីរយៈពេលវែង។ (ក្រាហ្វ ៣៨ និង ៣៩)

**ក្រាហ្វ ៣៨ ៖ ប្រភពទុនធនាគារ**

(ជាភាគរយ ឆ្នាំ២០១៣ - ឆ្នាំ២០១៩)




**ក្រាហ្វ ៣៩ ៖ ប្រភពទុនមូលនិធិកម្ចីធនាគារ**

(ខែធ្នូ ឆ្នាំ២០១៣ - ខែធ្នូ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

វិស័យមីក្រូហិរញ្ញវត្ថុបន្តពឹងផ្អែកលើមូលនិធិកម្ចីជាប្រភពទុនច្រើនជាងគ្រឹះស្ថានធនាគារ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានប្រភពទុនមកពី ប្រាក់បញ្ញើ មូលនិធិកម្ចី និងដើមទុន ដើម្បីទ្រទ្រង់ដល់សកម្មភាពផ្តល់សេវាហិរញ្ញវត្ថុ។ ប្រាក់បញ្ញើបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលបានរួមចំណែកប្រមាណ ៤៦%នៃប្រភពទុនសរុប ស្របពេលដែលមូលនិធិកម្ចីរួមចំណែកប្រមាណ ៣៦% នៃប្រភពទុនសរុប។ (ក្រាហ្វ ៤០ និង ៤១)

**ក្រាហ្វ ៤០ ៖ ប្រភពទុនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

(ជាភាគរយ ឆ្នាំ២០១៣ - ឆ្នាំ២០១៩)




**ក្រាហ្វ ៤១ ៖ ប្រភពទុនមូលនិធិកម្ចីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

(ខែធ្នូ ឆ្នាំ២០១៣ - ខែធ្នូ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ង- គុណភាពឥណទាន

គុណភាពឥណទានក្នុងប្រព័ន្ធធនាគារបន្តមានភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតទាបនៃអនុបាតឥណទានមិនដំណើរការរបស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ អនុបាតឥណទានមិនដំណើរការរបស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានកម្រិតទាប ប្រមាណ ២% និង ០,៤% រៀងគ្នា ខណៈអនុបាតរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានកម្រិត ៣,៣%។ ទោះយ៉ាងណា ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយអនុបាតឥណទានមិនដំណើរការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានថយចុះគួរឱ្យកត់សម្គាល់។

**ក្រាហ្វ ៤២ ៖ ឥណទានមិនដំណើរការ**

(ជាភាគរយ ត្រីមាសទី២ ឆ្នាំ២០១៣ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.២ ការអភិវឌ្ឍវិស័យមូលបត្រនិងវិស័យធានារ៉ាប់រង

### ក- ផ្សារមូលបត្រ

នៅឆ្នាំ២០១៩ ផ្សារមូលបត្រកម្ពុជា (CSX) មានប្រតិបត្តិការល្អបើទោះបីជាមិនមានការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO) ថ្មីក៏ដោយ។ មូលធននីយកម្មទីផ្សារបានកើនឡើង ៥៨,៥% ពី ១,៧៧ ទ្រីលានរៀលក្នុងឆ្នាំ២០១៨ ដល់ ២,៨ ទ្រីលានរៀលនៅឆ្នាំ២០១៩។

សន្ទស្សន៍ CSX បានកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារដំណើរការអាជីវកម្មយ៉ាងល្អនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) និងកំពង់ផែស្វយ័តភ្នំពេញ (PPAP)។ សន្ទស្សន៍នេះបានកើនឡើង ៥៨,៤% ពី ៤៨១ ដល់ ៧៦១,៧ (ក្រាហ្វ ៤៣)។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ តម្លៃភាគហ៊ុនរបស់ PAS បានបន្តកើនឡើងប្រមាណ ៩២,១% ស្របពេលដែលតម្លៃភាគហ៊ុនរបស់ PPAP មានកំណើន ៦២,៨% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

**ក្រាហ្វ ៤៣ ៖ សន្ទស្សន៍ផ្សារភាគហ៊ុន CSX**

(ឆ្នាំ២០១៥-២០១៩)




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

ជារួម ទីផ្សារភាគហ៊ុននៅកម្ពុជាកាន់តែមានភាពសកម្ម ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងគួរឱ្យកត់សម្គាល់នៃចំនួនប្រតិបត្តិការជួញដូរប្រចាំថ្ងៃ។ យោងតាមទិន្នន័យរបស់ CSX ទំហំការជួញដូរប្រចាំថ្ងៃជាមធ្យមបានកើនឡើងយ៉ាងខ្លាំងប្រមាណ ៤ដង ហើយតម្លៃជួញដូរជាមធ្យមបានកើនឡើងជិត ៦ដង ពី ១០៦,៩លានរៀល ដល់ ៦២៨,២លានរៀល។

## ខ- ផ្សារមូលបត្របំណុល

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួនបានបោះផ្សាយមូលបត្របំណុល ដែលបានរួមចំណែកអភិវឌ្ឍផ្សារមូលបត្របំណុលនៅកម្ពុជានិងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ ដែលបានបើកឱ្យជួញដូរលើទីផ្សារនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ បានប្រកាសលក់មូលបត្របំណុលជារៀលចំនួន ១.២០០.០០០ ឯកតា មានតម្លៃស្មើនឹង ១២៨ប៊ីលានរៀល ប៉ុន្តែមានត្រឹមតែ ៨៤៨.២១០ ឯកតា ត្រូវបានបោះផ្សាយ ដែលមានតម្លៃស្មើនឹង ៨៤,៨ប៊ីលានរៀល។ មូលបត្របំណុលរយៈពេល៣ឆ្នាំ ត្រូវបានវាយតម្លៃបានចំណាត់ថ្នាក់ B ពីក្រុមហ៊ុន S&P Global Ratings និងបានផ្តល់ឱ្យវិនិយោគិននូវការប្រាក់គូប៉ុង ៧,៧៥% និងបង់ការប្រាក់ត្រលប់មកវិញរៀងរាល់៦ខែម្តង។ លើសពីនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ដែលបានបើកឱ្យជួញដូរលើទីផ្សារនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ បានប្រកាសលក់មូលបត្របំណុលសាជីវកម្មចំនួន ៨០០.០០០ ឯកតា មានតម្លៃស្មើនឹង ៨០ប៊ីលានរៀល។ មូលបត្របំណុលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនេះមាន២ប្រភេទគឺ៖ មូលបត្របំណុលមានគូប៉ុង ចំនួន ២៦៤.០០០ ឯកតា ជាមួយនឹងការប្រាក់គូប៉ុង ៩% និងមូលបត្របំណុលផ្សារភ្ជាប់នឹងអត្រាប្តូរប្រាក់ ចំនួន ៥៣៦.០០០ ឯកតា ជាមួយនឹងការប្រាក់គូប៉ុង ៨%។ មូលបត្របំណុលទាំង២ប្រភេទនេះនឹងបង់ការប្រាក់ត្រលប់មកវិញរៀងរាល់ ៦ខែម្តង។

ដើម្បីលើកកម្ពស់ការអភិវឌ្ឍផ្សារមូលបត្រ រាជរដ្ឋាភិបាលបានផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់រយៈពេល ៣ ឆ្នាំដល់ស្ថាប័ននិងក្រុមហ៊ុនដែលបានចុះបញ្ជីនៅផ្សារមូលបត្រឬផ្សារមូលបត្របំណុល ដោយបន្ធូរពន្ធលើប្រាក់ចំណូលចំនួន ៥០% និងការអនុគ្រោះបំណុលពន្ធដែលរួមបញ្ចូលពន្ធលើប្រាក់ចំណូលទាំងស្រុង ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករស្នាក់នៅ និងអាករបំភ្លឺសាធារណៈ។

**តារាង ១ ៖ ក្រុមហ៊ុនបោះផ្សាយមូលបត្របំណុល**

| ក្រុមហ៊ុនបោះផ្សាយ មូលបត្របំណុល | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី | ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ |
|---|---|---|---|
| កាលបរិច្ឆេទបោះផ្សាយ | ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ | ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ | ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៩ |
| ប្រភេទមូលបត្របំណុល | មូលបត្របំណុលមានគូប៉ុង | - មូលបត្របំណុលមានគូប៉ុង<br>- មូលបត្របំណុលផ្សារភ្ជាប់នឹងអត្រាប្តូរប្រាក់ | មូលបត្របំណុលមានគូប៉ុង |
| តម្លៃមូលបត្របំណុលដែលបានបោះផ្សាយ | ១២០ ប៊ីលានរៀល<br>(៣០ លានដុល្លារអាមេរិក) | ៨០ ប៊ីលានរៀល<br>(២០ លានដុល្លារអាមេរិក) | ៨៤,៨ ប៊ីលានរៀល<br>(២១,២ លានដុល្លារអាមេរិក) |
| ប្រភេទរូបិយបណ្ណ | រៀល | រៀល | រៀល |
| រយៈពេលឥណប្រតិទាន (ឆ្នាំ) | ៣ឆ្នាំ | ៣ឆ្នាំ | ៣ឆ្នាំ |
| អត្រាគូប៉ុង (%) | ៨,៥០% | - ៩%<br>- ៨% | ៧,៧៥% |
| ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា) | ១.២០០.០០០ | ៨០០.០០០ | ៨៤៨.២១០ |
| តម្លៃចារឹកនៃមូលបត្របំណុល | ១០០.០០០ រៀលក្នុងមួយឯកតា | ១០០.០០០ រៀលក្នុងមួយឯកតា | ១០០.០០០ រៀលក្នុងមួយឯកតា |
| អ្នកធានាទិញមូលបត្រ | ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី | ក្រុមហ៊ុន យាន់តា ស៊ីយ្យូរីធី (ខេមបូឌា) ភីអិលស៊ី | ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយ្យូរីធី |

### គ- វិស័យធានារ៉ាប់រង

វិស័យធានារ៉ាប់រងបានបន្តកើនឡើង ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនបុព្វលាភដុលសរុបនៃធានារ៉ាប់រងទូទៅនិងធានារ៉ាប់រងអាយុជីវិត។ នៅឆ្នាំ២០១៩ ក្រុមហ៊ុនធានារ៉ាប់រងទូទៅមានចំនួន ១៣ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន ១១ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចចំនួន៧ កំពុងធ្វើប្រតិបត្តិការនៅកម្ពុជា។ បុព្វលាភសរុបបានកើនឡើង ៣១,៤% ក្នុងឆ្នាំ២០១៩ ដល់ ២៤៥,៨លានដុល្លារអាមេរិក។ បុព្វលាភធានារ៉ាប់រងទូទៅបានកើនឡើង ១៨,៨% ដែលភាគច្រើនត្រូវបានជំរុញដោយធានារ៉ាប់រងយានយន្ត សុខភាព និងទ្រព្យសម្បត្តិ។ លើសពីនេះ បុព្វលាភធានារ៉ាប់រងអាយុជីវិតបានកើនឡើង ៤២,៤% ដោយសារការកើនឡើងនៃការលក់កិច្ចសន្យាទាយជ្ជទាន (Endowment Policy)។

លើសពីនេះ ចំនួនទឹកប្រាក់សរុបនៃការផ្ដល់សំណងរបស់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងអាយុជីវិត បានកើនឡើងក្នុងឆ្នាំ២០១៩។ ការផ្ដល់សំណងរបស់ក្រុមហ៊ុនធានារ៉ាប់រងទូទៅមានចំនួន ២៩,១លានដុល្លារអាមេរិក ធៀបនឹងឆ្នាំ២០១៨ ប្រមាណ ១៩,៨លានដុល្លារអាមេរិក។ ដូច្នេះ អនុបាតនៃការផ្ដល់សំណងបានកើនឡើងដល់ ២៨,៣% ក្នុងឆ្នាំ២០១៩ (២២,៨% ក្នុងឆ្នាំ២០១៨)។ ការផ្ដល់សំណងរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតបានកើនឡើង ១០៨% ដល់ ៤,៨លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ (ជាមួយនឹងអនុបាតនៃការផ្ដល់សំណង ២,៣%)។

សមាមាត្រនៃវិស័យធានារ៉ាប់រងនៅតែមានកម្រិតតិចតួចក្នុងប្រព័ន្ធហិរញ្ញវត្ថុ ប៉ុន្តែមានការរីកចម្រើនយ៉ាងឆាប់រហ័ស។ ផ្អែកតាមការគណនារបស់ IMF វិស័យធានារ៉ាប់រងបានរួមចំណែកប្រមាណ ០,៥% នៃទ្រព្យសកម្មក្នុងវិស័យហិរញ្ញវត្ថុសរុប។

**ក្រាហ្វ ៤៤ ៖ បុព្វលាភដុល**
(ជាលានដុល្លារអាមេរិក, ឆ្នាំ២០១៦ - ឆ្នាំ២០១៩)




**ក្រាហ្វ ៤៥ ៖ សំណងធានារ៉ាប់រងដុល**
(ជាលានដុល្លារអាមេរិក, ឆ្នាំ២០១៦ - ឆ្នាំ២០១៩)




ប្រភព៖ សមាគមធានារ៉ាប់រងកម្ពុជា

## ៣. ទំនាក់ទំនងម៉ាក្រូហិរញ្ញវត្ថុ និងហានិភ័យប្រឈមចំពោះស្ថិរភាពហិរញ្ញវត្ថុ

យ៉ាងណាមិញ សូចនាករសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយចំនួនបានបង្ហាញពីសញ្ញាថមថយនាប៉ុន្មានត្រីមាសចុងក្រោយ ដែលតម្រូវឱ្យមានការវិភាគកាន់តែស៊ីជម្រៅលើទំនាក់ទំនងម៉ាក្រូហិរញ្ញវត្ថុ និងហានិភ័យប្រឈមចំពោះស្ថិរភាពហិរញ្ញវត្ថុ។ ការបង្កើតគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា បានជំរុញឱ្យមានយន្តការផ្លូវការមួយក្នុងការចែករំលែកទិន្នន័យ និងការសម្របសម្រួលគោលនយោបាយនានារវាង ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មការមូលបត្រកម្ពុជា។

### ៣.១ ការវិភាគតាមតារាងតុល្យការ

**ក្រាហ្វ ៤៦ ៖ ស្ថានភាពហិរញ្ញវត្ថុរួមតាមវិស័យឆ្នាំ២០១៩**

(គិតជាប៊ីលានដុល្លារអាមេរិក)




<u>កំណត់សម្គាល់ ៖</u>

- *ទំហំរង្វង់ តំណាងឱ្យទំហំទឹកប្រាក់សរុបនៃទ្រព្យសកម្មនិងទ្រព្យអកម្មរបស់វិស័យនីមួយៗ*
- *ពណ៌នៃខ្សែដែលចេញពីវិស័យមួយ ទៅវិស័យផ្សេងទៀត តំណាងឱ្យបំណុលត្រូវទារពីវិស័យទាំងនោះ*

*ប្រភព៖ ការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា*

គិតត្រឹមចុងឆ្នាំ២០១៩ លទ្ធផលនៃការវិភាគតាមតារាងតុល្យការ[១] (BSA) បានបង្ហាញពីភាពប្រទាក់ក្រឡាហិរញ្ញវត្ថុខ្លាំងរវាងគ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត (ODCs) គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ (NFCs) និងវិស័យក្រៅប្រទេស (ក្រាហ្វ ៤៦)។ ODCs មានបំណុលត្រូវទារសុទ្ធពីវិស័យផ្សេងទៀតចំនួន២ប៊ីលានដុល្លារអាមេរិក (៧,៦% នៃផ.ស.ស) ដែលបង្ហាញពីតួនាទីកាន់តែសំខាន់របស់ ODCs ក្នុងការអភិវឌ្ឍនិងគាំទ្រកំណើនសេដ្ឋកិច្ច។ ប្រភពទុននៃ ODCs ភាគច្រើនបានមកពីអង្គភាពគ្រួសារ (២៧,៤ ប៊ីលានដុល្លារអាមេរិក) វិស័យខាងក្រៅ (៧,៦ ប៊ីលានដុល្លារអាមេរិក) និងគ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ (៧,៤ ប៊ីលានដុល្លារអាមេរិក) ដែលវិស័យទាំង ៣ នេះ បានរួមចំណែក ៩៥% នៃលំហូរចូលដើមទុនសរុបដល់ ODCs។ ម្យ៉ាងទៀត បំណុលត្រូវទាររបស់ ODCs លើវិស័យផ្សេងទៀតបានកើនដល់ ៤៦,៩ ប៊ីលានដុល្លារអាមេរិក (១៧៤% នៃផ.ស.ស. ឬ ២៩,៣% នៃបំណុលត្រូវទារសរុប) ហើយភាគច្រើននៃបំណុលទាំងនេះត្រូវបានផ្តល់ទៅវិស័យមិនមែនហិរញ្ញវត្ថុ ដែលមានចំណែកប្រមាណ ៤៧% នៃទ្រព្យសកម្មសរុបរបស់ ODCs ។ លំហូរចេញទៅកាន់អង្គភាពគ្រួសារដែលជាប្រភពទុនដ៏សំខាន់របស់ ODCs បានរួមចំណែកត្រឹម ១៩% នៃលំហូរចេញសរុប ស្របពេលដែលលំហូរចេញទៅកាន់វិស័យខាងក្រៅបានរួមចំណែក ៨% (៣,៨ ប៊ីលានដុល្លារអាមេរិក)។ លំហូរចូលពី

[១] វិធីសាស្ត្រវិភាគតាមតារាងតុល្យការ គឺជាក្របខ័ណ្ឌវិភាគជាប្រព័ន្ធដើម្បីស្វែងរកនូវចំណុចខ្សោយនៃតារាងតុល្យការដែលជាប្រភពនៃការរីករាលដាលនៃវិបត្តិ។ វិធីសាស្ត្រនេះផ្តោតលើអថេរជាលេខស្តុក (stock variables) នៅក្នុងតារាងតុល្យការតាមវិស័យ និងតារាងតុល្យការរួមរបស់ប្រទេស។ វិធីសាស្ត្រនេះគ្របដណ្តប់លើវិស័យចំនួន ៧ រួមមាន៖ រដ្ឋាភិបាល ធនាគារកណ្តាល គ្រឹះស្ថានប្រាក់បញ្ញើផ្សេងទៀត គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុផ្សេងទៀត អង្គភាពគ្រួសារ និងវិស័យខាងក្រៅ។

ក្រៅប្រទេសមានប្រមាណ ៧,៦ ប៊ីលានដុល្លារអាមេរិក ដែលភាគច្រើនជាកម្ចីពីក្រៅប្រទេសនិងប្រាក់បញ្ញើអនិវាសជន។

បំណុលត្រូវទារសុទ្ធពីវិស័យខាងក្រៅទៅលើវិស័យផ្សេងទៀតនៅកម្ពុជា បានកើនឡើងដល់ ១៧ ប៊ីលានដុល្លារអាមេរិក ដោយសារកំណើនបំណុលរបស់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ និងរដ្ឋាភិបាល។ គិតត្រឹមឆ្នាំ២០១៩ រំហូរចូលពីវិស័យខាងក្រៅទៅកាន់ NFCs មាន ២៧,៧ ប៊ីលានដុល្លារអាមេរិក ខណៈរំហូរចេញមានកម្រិតទាបត្រឹម ៣,៦ ប៊ីលានដុល្លារអាមេរិក។ ទន្ទឹមនេះ ភាពប្រទាក់ក្រឡាហិរញ្ញវត្ថុរវាងរដ្ឋាភិបាលនិងវិស័យខាងក្រៅបានបង្ហាញថា រំហូរចូលពីក្រៅប្រទេសមកកាន់រាជរដ្ឋាភិបាលកម្ពុជាមាន ៧,៥ ប៊ីលានដុល្លារអាមេរិក ដែលភាគច្រើនជាជំនួយឥតសំណងនិងកម្ចីសម្បទាន ខណៈរាជរដ្ឋាភិបាលកម្ពុជាពុំមានបំណុលត្រូវទារពីវិស័យខាងក្រៅនោះឡើយ ដោយសារអវត្តមាននៃមូលបត្របំណុលរដ្ឋាភិបាល។

ស្ថានភាពហិរញ្ញវត្ថុអន្តរវិស័យរវាងឆ្នាំ២០១៥ និងឆ្នាំ២០១៩ បានបង្ហាញពីនិន្នាការប្រហាក់ប្រហែលគ្នា ប៉ុន្តែទំហំនិងតម្លៃប្រតិបត្តិការនៃវិស័យទាំងនោះបានកើនឡើងគួរឱ្យកត់សម្គាល់។ ODCs បានដើរតួនាទីកាន់តែសកម្មក្នុងការកៀរគរធនធាន ពិសេសពីអង្គភាពគ្រួសារ ហើយបានផ្តល់មូលនិធិទាំងនោះមួយផ្នែកធំទៅកាន់ NFCs។ រំហូរចូលពីវិស័យផ្សេងៗមកកាន់ ODCs បានកើនឡើងយ៉ាងឆាប់រហ័សពី ២២,៤ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៥ ដល់ ៤៨,៨ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៩ ខណៈរំហូរចេញបានកើនដល់ ៤៦,៩ ប៊ីលានដុល្លារអាមេរិក ពី ២២,៦ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៥។ ក្រៅពីនេះ បំណុលត្រូវទារសុទ្ធរបស់វិស័យខាងក្រៅមកលើវិស័យផ្សេងទៀតនៅកម្ពុជាក៏បានកើនឡើងគួរកត់សម្គាល់ផងដែរ ដែលឆ្លុះបញ្ចាំងតាមរយៈរំហូរចូលពីវិស័យខាងក្រៅប្រមាណពី ២៧,៩ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៥ ដល់ ៤៣,៤ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៩ ខណៈរំហូរចេញបានកើនពី ១៧,២ ប៊ីលានដុល្លារអាមេរិក ដល់ ២៦,២ ប៊ីលានដុល្លារអាមេរិក។ រំហូរចូលមូលនិធិពីក្រៅប្រទេសភាគច្រើនត្រូវបានបែងចែកទៅកាន់ NFCs ដែលបានធ្វើឱ្យបំណុលសុទ្ធរបស់វិស័យនេះបានកើនឡើងពី ១០,១ ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ២០១៥ ដល់ ១៧ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៩ ដែលភាគច្រើនជាការវិនិយោគផ្ទាល់បរទេសនៅកម្ពុជា។

## ក្រាហ្វ ៤៧ ៖ ស្ថានភាពហិរញ្ញវត្ថុអន្តរវិស័យ

(ឆ្នាំ២០១៥ និងឆ្នាំ២០១៩)




*កំណត់សម្គាល់:*

- *វិស័យសេដ្ឋកិច្ចដែលរំលេចដោយពណ៌ ក្រហម សំដៅលើឥណទាយិក (Net debtor) ខណៈដែលវិស័យសេដ្ឋកិច្ចដែលរំលេចដោយពណ៌ បៃតង សំដៅលើឥណទាយក (Net Creditor)*
- *ទំហំរង្វង់ តំណាងឱ្យទំហំស្ថានភាពសុទ្ធ (Net Position) របស់វិស័យនីមួយៗ*
- *សញ្ញាព្រួញដែលចេញពីវិស័យមួយ ទៅវិស័យផ្សេងទៀត តំណាងឱ្យបំណុលត្រូវទារពីវិស័យទាំងនោះ*

ប្រភព៖ ការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## ៣.២ កំណើនឥណទាន

### ក- កំណើនឥណទាន និងគម្លាតឥណទានធៀបនឹងផ.ស.ស

វិស័យហិរញ្ញវត្ថុនៅកម្ពុជានៅតែបន្តរក្សាបានសុខភាពល្អ ប៉ុន្តែកំណើនឥណទាននៅក្នុងប្រព័ន្ធធនាគារនៅតែមានកម្រិតខ្ពស់។ គិតត្រឹមឆ្នាំ២០១៩ ឥណទានក្នុងប្រព័ន្ធធនាគារមានកំណើន ២៥,៥% ខ្ពស់ជាងឆ្នាំ២០១៨ (២៤,៩%) ក្នុងនោះកំណើនឥណទានរបស់គ្រឹះស្ថានធនាគារហាក់មានល្បឿនយឺត ខណៈដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅតែមានកំណើនខ្ពស់។

## ក្រាហ្វ ៤៨ ៖ កំណើនឥណទានក្នុងប្រព័ន្ធធនាគារ

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ត្រីមាសទី១ ២០១៦ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

កំណើនឥណទានបានធ្វើឱ្យគម្លាតឥណទានធៀបនឹងផ.ស.ស កើនជាលំដាប់ដល់ ១៩% ដែលខ្ពស់ជាងកម្រិតកំណត់ដោយធនាគារសម្រាប់ការទូទាត់អន្តរជាតិ BIS (១០%)។ យោងតាមគណៈកម្មាធិការបាសែលស្តីពីការត្រួតពិនិត្យធនាគារបានបង្ហាញថា វិស័យធនាគារអាចប្រឈមនឹងហានិភ័យជាប្រព័ន្ធ ប្រសិនបើគម្លាតឥណទានធៀបនឹងផ.ស.ស មានកម្រិតខ្ពស់ ហើយទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital Buffer) គួរតែត្រូវបានដាក់ឱ្យអនុវត្តដែលស្មើនឹង ២,៥% នៃទ្រព្យសកម្មថ្លឹងតាមកម្រិតហានិភ័យ (Risk-weighted Assets)[២]។ យ៉ាងណាមិញ ដោយសារប្រទេសកម្ពុជាជាប្រទេសមានកំណើនសេដ្ឋកិច្ចលឿន ស្របពេលដែលទីផ្សារហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលកំពុងអភិវឌ្ឍន៍នៅឡើយ កម្ពុជានៅតែត្រូវការឥណទានពីប្រព័ន្ធធនាគារដើម្បីទ្រទ្រង់ដល់សកម្មភាពនានាក្នុងវិស័យសេដ្ឋកិច្ច។

**ក្រាហ្វ ៤៩ ៖ អនុបាតឥណទានធៀបនឹង ផ.ស.ស និងគម្លាតឥណទាន**

(គិតជាភាគរយ, ត្រីមាសទី១ ឆ្នាំ២០១០-ត្រីមាសទី៤ ឆ្នាំ២០១៩)




*សម្គាល់ ៖ ឥណទានសរុប គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ + ធនាគារ =, គម្លាតត្រូវបានគណនាដោយប្រើ one-sided HP filter ជាមួយ lambda ចំនួន ៤០០,០០០*

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ខ. ឥណទានតាមវិស័យ

ឥណទានគ្រឹះស្ថានធនាគារបានបែងចែកទៅកាន់វិស័យផ្សេងៗក្នុងសេដ្ឋកិច្ច ហើយមាននិន្នាការកើនឡើងលឿនទៅលើវិស័យសំណង់និងអចលនទ្រព្យ។ ឥណទានគ្រឹះស្ថានធនាគារបានកើនឡើង ២៣,៧% ក្នុងឆ្នាំ២០១៩ ធៀបនឹងកំណើនដូចគ្នានៅឆ្នាំ២០១៨ ក្នុងនោះរួមចំណែកដោយវិស័យ៖ ការជួញដូរដុំនិងរាយ (៥,៨%) ឥណទានទិញផ្ទះ (៤,៤%) អចលនទ្រព្យ (៣,២%) ការប្រើប្រាស់របស់ក្រុមគ្រួសារ (៣%) សំណង់ (៣%) និងផ្សេងៗ (៤,៣%)។ ការរួមចំណែករបស់វិស័យកម្មន្តសាល និងវិស័យកសិកម្មនៅតែមានទំហំតូចនៅក្នុងកំណើនឥណទាន ដោយមានកម្រិតត្រឹមតែ ០,២% និង ០,៤% រៀងគ្នា។

[២] Geršl, A and J Seidler. (2012). Excessive credit growth and countercyclical capital buffers in Basel III: An empirical evidence from central and east European countries. Economic Studies and Analyses, no 6(2).

### ក្រាហ្វ ៥០ ៖ ការរួមចំណែកនៃឥណទានតាមវិស័យទៅកាន់កំណើនឥណទានធនាគារសរុប

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ត្រីមាសទី១ ២០១៦ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ស្របពេលដែលសេដ្ឋកិច្ចមានសកម្មភាពខ្លាំងក្នុងឆ្នាំ២០១៩ ឥណទានទៅកាន់វិស័យពាណិជ្ជកម្មនិងជួញដូរបន្តមានកំណើនខ្ពស់។ ឥណទានទៅកាន់វិស័យជួញដូរដុំនិងរាយមានចំណែកប្រមាណ ២៧,៧% នៃឥណទានសរុប និងមានកំណើន ២២% និង ២១% រៀងគ្នា។ កំណើនក្នុងវិស័យនេះបានឆ្លុះបញ្ចាំងពីកំណើនជំនឿទុកចិត្តពីវិនិយោគិន ជាពិសេសការកើនឡើងនៃការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូចនិងមធ្យម។

ចំណែកឥណទានទិញផ្ទះ វិស័យសំណង់ និងវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យបានកើនឡើងជាបន្តបន្ទាប់ ដោយសារការកើនឡើងនៃតម្រូវការក្នុងស្រុក និងវំហូរចូលមូលធន ជាពិសេសពីប្រទេសចិន។ កំណើនសេដ្ឋកិច្ចកម្ពុជានាពេលកន្លងមកបានធ្វើឱ្យចំណូលប្រជាជនមធ្យមក្នុង១នាក់កើនពី ៨២៥ ដុល្លារអាមេរិក ក្នុងឆ្នាំ២០១១ ដល់ ១.២០៥ ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨[៣] និងបានប្រែក្លាយពីប្រទេសមានចំណូលទាបទៅជាប្រទេសចំណូលមធ្យមកម្រិតទាប។ ការកើនឡើងនៃប្រាក់ចំណូលរបស់ប្រជាជនបានជំរុញឱ្យមានតម្រូវការលំនៅដ្ឋាន ដែលបានឆ្លុះបញ្ចាំងតាមរយៈកំណើនឥណទានទិញផ្ទះ ៤២,៣% ក្នុងឆ្នាំ២០១៩ ធៀបនឹង ៣៥,៦% ក្នុងឆ្នាំ២០១៨។ ទន្ទឹមនេះ ដោយសារកម្ពុជាទទួលបានវំហូរមូលធនច្រើនជាពិសេសពីវិនិយោគិនចិនទៅក្នុងវិស័យសំណង់ និងវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ ឥណទានទៅវិស័យទាំងនេះបានកើនឡើងយ៉ាងឆាប់រហ័ស ដោយឥណទានទៅកាន់វិស័យសំណង់មានកំណើនពី ២២% ក្នុងឆ្នាំ២០១៨ ដល់ ៣០,៥% ក្នុងឆ្នាំ២០១៩ និងឥណទានទៅវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យនៅមានកំណើនខ្ពស់ ទោះបីជាបានថមថយល្បឿនបន្តិចពី ៥៥% ក្នុងឆ្នាំ២០១៨ មកត្រឹម ៤២,៤% ក្នុងឆ្នាំ២០១៩ ក៏ដោយ។ (ក្រាហ្វ ៥២)

---

[៣] ប្រភព៖ ធនាគារពិភពលោក គេហទំព័រ៖ https://data.worldbank.org/indicator/NY.GDP.PCAP.KD?locations=KH

**ក្រាហ្វ ៥១ ៖ ចំណែកឥណទានធនាគារតាមវិស័យ**

(គិតជាភាគរយ, ឆ្នាំ២០១៧, ២០១៨ និង ២០១៩)




**ក្រាហ្វ ៥២ ៖ កំណើនឥណទានក្នុងវិស័យចម្បងៗ**

(គិតជាភាគរយ, ត្រីមាសទី១ ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

យ៉ាងណាមិញ ក្នុងឆ្នាំ២០១៩ ឥណទានទៅកាន់វិស័យទេសចរណ៍បានថយចុះក្នុងរយៈពេលបីត្រីមាសចុងក្រោយ ស្របពេលដែលចំនួនភ្ញៀវទេសចរបានធ្លាក់ចុះ។ ឥណទានទៅកាន់សណ្ឋាគារ និងភោជនីយដ្ឋានមានកំណើនខ្ពស់ក្នុងឆ្នាំ២០១៨ (៣០,៩%) ប៉ុន្តែកំណើននេះមានត្រឹម ១៧,៧% ក្នុងឆ្នាំ២០១៩ ស្របពេលដែលកំណើនភ្ញៀវទេសចរក៏បានថយចុះមកត្រឹម ៦,៦% ក្នុងឆ្នាំ២០១៩ ធៀបនឹងឆ្នាំ២០១៨ (១០,៧%)។

ឥណទានទៅកាន់វិស័យកម្មន្តសាលមាននិន្នាការថយចុះ និងមានកំណើនទាបក្នុងឆ្នាំ២០១៩។ ឥណទានទៅវិស័យកម្មន្តសាលបានកើនឡើងពី ៣,៥% ក្នុងត្រីមាសទី១ ដល់ ១៤,២% ក្នុងត្រីមាសទី២ និងកំណើនបានថយចុះមកវិញត្រឹម ៣,៦% គិតត្រឹមចុងឆ្នាំ២០១៩ ដែលបណ្តាលមកពីការធ្លាក់ចុះតម្រូវការខាងក្រៅ ជាពិសេសទាក់ទងនឹងភាពតានតឹងផ្នែកពាណិជ្ជកម្ម និងកំណើនទាបនៃសេដ្ឋកិច្ចពិភពលោក។

ឥណទានទៅកាន់វិស័យកសិកម្មបានថមថយជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០១៧ ដោយសារកត្តាអាកាសធាតុមិនអំណោយផល និងផលិតភាពនៅមានកម្រិតទាប។ ចំណែកឥណទានទៅវិស័យកសិកម្មធៀបនឹងឥណទានសរុប បានថយចុះមក ៨% ក្នុងឆ្នាំ២០១៩ ធៀបនឹង ៩% ឆ្នាំ២០១៨ និង ១១% ឆ្នាំ២០១៧ ហើយកំណើនឥណទានក្នុងវិស័យនេះបានថមថយពី ១៥,២% នៅឆ្នាំ២០១៧ មក ៨,៥% ក្នុងឆ្នាំ២០១៩។ ការធ្លាក់ចុះនៃកំណើនឥណទានទៅវិស័យនេះអាចបណ្តាលមកពីការថយចុះនៃកំណើនការប្រមូលកសិផល ដែលមានកម្រិតជាមធ្យម ១% ក្នុងឆ្នាំ២០១៤-២០១៨ ថយចុះពីកំណើនជាមធ្យម ៣,៧% ក្នុងឆ្នាំ២០០៩-២០១៣ ដោយសារភាពមិនអំណោយផលពីអាកាសធាតុ និងការធ្លាក់ចុះនៃតម្លៃកសិផល[៤]។ ទោះបីជាប្រទេសកម្ពុជាជាប្រទេសដែលមានប្រជាជនវ័យក្មេងច្រើន តែកំណើនប្រជាជនវ័យក្មេងមកធ្វើការនៅទីក្រុងនិងក្រៅប្រទេសបានកើនឡើង ដែលធ្វើឱ្យការចូលរួមចំណែកកម្លាំងពលកម្មក្នុងវិស័យកសិកម្មមានកម្រិតទាប និងបានប៉ះពាល់ដល់ផលិតភាពក្នុងវិស័យនេះ[៥]។ (ក្រាហ្វ ៥១)

[៤] Lao, P. (2019). Cambodia's Agriculture Productivity: Challenges and Policy Direction. Research working paper.

[៥] RGC (2019). Modernizing agriculture sector: Long-term vision and policy orientation. Technical report.

**ក្រាហ្វ ៥៣ ៖ ចំណែកឥណទានធនាគារតាមវិស័យ**

(គិតជាភាគរយ, ឆ្នាំ២០១៧, ២០១៨ និង ២០១៩)




**ក្រាហ្វ ៥៤ ៖ កំណើនឥណទានក្នុងវិស័យចម្បងៗ**

(គិតជាភាគរយ, ត្រីមាសទី១ ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ឥណទានទៅកាន់ក្រុមគ្រួសារបន្តមានកំណើនខ្ពស់ ទោះបីជាបានថមថយកំណើនបន្តិចពី ៤២% ក្នុងឆ្នាំ២០១៨ មក ៣៨,៧% ក្នុងឆ្នាំ២០១៩ ក្នុងនោះ ឥណទានទិញផ្ទះរួមចំណែកធំជាងគេក្នុងកំណើន ប្រមាណ ២៣% ការឱ្យខ្ចីជាបុគ្គល ១៥,៤៥% និងការឱ្យខ្ចីតាមបណ្ណឥណទាន ០,២៥%។ ទន្ទឹមនេះ កំណើនឥណទានទិញផ្ទះបានកើនឡើងពី ៣៦% ក្នុងឆ្នាំ២០១៨ មក ៤១,៣% ក្នុងឆ្នាំ២០១៩ ដោយសារការកើនឡើងតម្រូវការលំនៅដ្ឋាន ជាពិសេសពីក្រុមគ្រួសារដែលមានចំណូលមធ្យម ព្រមទាំងការកើនឡើងនៃភាពប្រកួតប្រជែងក្នុងប្រព័ន្ធធនាគារ ដែលបានធ្វើឱ្យអត្រាការប្រាក់ទាប និងមានភាពទាក់ទាញជាងមុន។

យ៉ាងណាមិញ ឥណទានសាជីវកម្មបន្តចូលរួមចំណែកយ៉ាងសកម្មក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច ដោយក្នុងឆ្នាំ២០១៩ មានកំណើន ២២,៨% ធៀបនឹង ២០% ក្នុងឆ្នាំ២០១៨។ កំណើននេះត្រូវបានគាំទ្រពីវិស័យសំខាន់ៗរួមមាន៖ វិស័យជួញដូររាយ (៦,៣%), អចលនទ្រព្យ (៥,៧%) សំណង់ (៥,២%) និងវិស័យជួញដូរដុំ (៤%) ខណៈការរួមចំណែកពីវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន និងកម្មន្តសាលបន្តមានកម្រិតតិចតួច។

**ក្រាហ្វ ៥៥ ៖ ចំណែកនៃកំណើនឥណទានក្រុមគ្រួសារ**

(គិតជាភាគរយ, ត្រីមាសទី១ ២០១៦ - ត្រីមាសទី៤ ឆ្នាំ២០១៩)




**ក្រាហ្វ ៥៦ ៖ ចំណែកនៃកំណើនឥណទានសាជីវកម្ម**

(គិតជាភាគរយ, ត្រីមាសទី១ ២០១៦ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

វិស័យមីក្រូហិរញ្ញវត្ថុនៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចតាមរយៈការបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានកំណើនឥណទានពី ៣០,៧% ក្នុងឆ្នាំ២០១៨ ដល់ ៣២,៥% ក្នុងឆ្នាំ២០១៩ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានកំណើនឥណទានពី ២៥,៨% ដល់ ៣៩,៨% នៅក្នុងរយៈពេលដូចគ្នា។ ឥណទានក្នុងវិស័យមីក្រូហិរញ្ញវត្ថុត្រូវបានគាំទ្រដោយឥណទានទៅកាន់ក្រុមគ្រួសារ និងឥណទានទៅកាន់វិស័យសេវាកម្មនិងពាណិជ្ជកម្ម។ ការកើនឡើងនៃលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុបានការពារប្រជាជនដោយបង្វែរពីឥណទានក្រៅផ្លូវការដែលមានអត្រាការប្រាក់ខ្ពស់ហួសហេតុ និងងាកមកប្រើប្រាស់ឥណទានផ្លូវការពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គួររំលេចថា ចំណែកនៃឥណទានក្រៅផ្លូវការបានថយចុះពី ៣២% នៅឆ្នាំ២០០៤ មក ៦% នៅឆ្នាំ២០១៦[៦]។

កំណើនឥណទានក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ជាពិសេសឥណទានផ្តល់ដល់ប្រជាជននៅតាមជនបទបានជំរុញការប្រើប្រាស់។ ក្នុងឆ្នាំ២០១៩ ឥណទានទៅក្រុមគ្រួសារបានរួមចំណែកធំជាងគេក្នុងឥណទានរបស់វិស័យមីក្រូហិរញ្ញវត្ថុ (៣៣,៣% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៣៩% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) ក្នុងនោះបានរួមចំណែកប្រមាណ ៨,៧% នៃកំណើនឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ១២,៦% នៃកំណើនឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ការសិក្សាជាច្រើនបានបង្ហាញថា ឥណទានពីវិស័យមីក្រូហិរញ្ញវត្ថុបានបង្កើនចំណូលប្រជាពលរដ្ឋ និងរួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា[៧]។

យ៉ាងណាមិញ ការកើនឡើងបំណុលច្រើនលើសពីចំណូលនឹងអាចធ្វើឱ្យប្រជាជនដែលបានទទួលឥណទានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចធ្លាក់ក្នុងស្ថានភាពបំណុលលើសលប់ និងបង្ហាញពីកង្វះខាតចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ប្រជាជន។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ចំពោះការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ តាមរយៈការអនុវត្តគម្រោងមួយចំនួនរួមមាន៖ យុទ្ធនាការ "តោះ! និយាយពីលុយ" និងបានបង្កើតជាវីដេអូ និងសៀវភៅតុក្កតាអប់រំប្រជាពលរដ្ឋពីការរៀបចំហិរញ្ញវត្ថុផ្ទាល់ខ្លួន។ ធនាគារជាតិនៃកម្ពុជាក៏បានសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរពាក់ព័ន្ធដូចជា ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដាក់បញ្ចូលការអប់រំផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ និងក្រសួងកិច្ចការនារី ក្នុងការពង្រឹងការអប់រំហិរញ្ញវត្ថុសម្រាប់ស្ត្រី។

[៦] Pimhidzai, O., Tong, K., Anantavrasilpa, R., Popovic, A., Mel, S., & Sanchez Martin, M. E. (2019). Microfinance and Household Welfare: Cambodia Policy Note. World Bank’s report.

[៧] ឧទាហរណ៍៖ 1- Runsinarith, P. (2014). The impacts of microcredit on poverty reduction: Evidence from Cambodian rural villages. Philippine Review of Economics, 51(2), 121-150; 2- Roth, T. M. S., Araar, A., Sry, B., & Phann, D. (2017). The Dynamics of Microcredit Borrowings in Cambodia. Partnership for Economic Policy Working Paper, (2017-17); and 3- Pimhidzai, O., Tong, K., Anantavrasilpa, R., Popovic, A., Mel, S., & Sanchez Martin, M. E. (2019). Microfinance and Household Welfare: Cambodia Policy Note. World Bank’s report.

**ក្រាហ្វ ៥៧ ៖ ការរួមចំណែកកំណើនឥណទាន**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើតាមវិស័យ**
(គិតជាភាគរយ, ត្រីមាសទី១ ឆ្នាំ២០១៦-ត្រីមាសទី៤ ឆ្នាំ២០១៩)




**ក្រាហ្វ ៥៨ ៖ ការរួមចំណែកកំណើនឥណទាន**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមវិស័យ**
(គិតជាភាគរយ, ត្រីមាសទី១ ឆ្នាំ២០១៦-ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

បន្ទាប់ពីការវិភាគលើការផ្តល់ឥណទានតាមវិស័យ ការពិនិត្យមើលលើសូចនាករផ្សេងទៀតដូចជាអនុបាតឥណទានមិនដំណើរការ (NPL) មានភាពចាំបាច់ណាស់សម្រាប់វាយតម្លៃពីហានិភ័យហិរញ្ញវត្ថុ។

## គ. គុណភាពឥណទានតាមវិស័យ

អនុបាតឥណទានមិនដំណើរការរបស់គ្រឹះស្ថានធនាគារមានកម្រិត ២% ក្នុងឆ្នាំ២០១៩ ថយចុះបន្តិចធៀបនឹងឆ្នាំ២០១៨ (២,២%)។ ទោះយ៉ាងណា អនុបាតឥណទានមិនដំណើរការក្នុងវិស័យកសិកម្ម និងកម្មន្តសាលនៅបន្តមានកម្រិតខ្ពស់ ៧,៥% និង ៣% រៀងគ្នា ខណៈអនុបាតនេះក្នុងវិស័យផ្សេងទៀតមានកម្រិតទាប។ អនុបាតឥណទានមិនដំណើរការក្នុងវិស័យកសិកម្មមិនត្រឹមតែមានកម្រិតខ្ពស់ទេ តែក៏មាននិន្នាការកើនឡើងជាបន្តបន្ទាប់ផងដែរចាប់តាំងពីឆ្នាំ២០១៤ ស្របពេលដែលផលិតភាពក្នុងវិស័យនេះមានការថយចុះ។ កម្រិតខ្ពស់នេះក៏ប៉ះពាល់ដល់ការសម្រេចចិត្តក្នុងការផ្តល់ឥណទានបន្ថែមរបស់គ្រឹះស្ថានធនាគារទៅក្នុងវិស័យកសិកម្ម ដែលធ្វើឱ្យកំណើនឥណទានក្នុងវិស័យនេះមានការថយចុះ។

**ក្រាហ្វ ៥៩ ៖ អនុបាតឥណទានមិនដំណើរការតាមវិស័យរបស់គ្រឹះស្ថានធនាគារ**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ត្រីមាសទី៤ ២០១៤ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

អនុបាតឥណទានមិនដំណើរការក្នុងវិស័យអចលនទ្រព្យ និងឥណទានទិញផ្ទះនៅមានកម្រិតទាប ក្នុងនោះវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យមានកម្រិត ០,៨% និងឥណទានទិញផ្ទះ ០,៥%។ គួររំលេចថា អនុបាតឥណទានមិនដំណើរការសម្រាប់វិស័យសំណង់មាននិន្នាការធ្លាក់ចុះក្នុងឆ្នាំ២០១៩ មកត្រឹម ២,៣% ធៀបនឹង ៣,៦% ក្នុងឆ្នាំ២០១៨។ ទោះបីជាអនុបាតឥណទានមិនដំណើរការនៅមានកម្រិតទាប ធនាគារជាតិនៃកម្ពុជានៅតែបន្តតាមដានការវិវត្តរបស់វិស័យអចលនទ្រព្យយ៉ាងយកចិត្តទុកដាក់ ដោយសារកំណើនឥណទានក្នុងវិស័យទាំងនេះមានកម្រិតខ្ពស់។

**ក្រាហ្វ ៦០ ៖ អនុបាតឥណទានមិនដំណើរការក្នុងវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ និងការប្រើប្រាស់របស់ក្រុមគ្រួសារ**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ត្រីមាសទី៤ ២០១៤ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៣.៣ វិធានការម៉ាក្រូប្រុងប្រយ័ត្ន

នៅក្នុងឆ្នាំ២០១៩នេះ វិធានការម៉ាក្រូប្រុងប្រយ័ត្នមួយចំនួនដែលត្រូវបានដាក់ឱ្យអនុវត្តដើម្បីពង្រឹងភាពធន់នៃប្រព័ន្ធធនាគារ រួមមាន៖

- ការកំណត់ទ្រនាប់ដើមទុន ដែលរួមមានទ្រនាប់ដើមទុនខនស៊ើវេសិន (Capital Conservation Buffer –CCB) និងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital Buffer – CCyB) ត្រូវបានបង្កើតឡើងក្នុងគោលបំណងពង្រឹងភាពធន់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយបន្ថែមលើអនុបាតសាធនភាពអប្បបរមាចំនួន ១៥%។ គួរបញ្ជាក់ថា ទ្រនាប់ដើមទុនខនស៊ើវេសិន គឺជាដើមទុនបន្ថែមដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាទុកតាមរយៈការបន្ថែមដើមទុន និង/ឬផ្ទេរពីប្រាក់ចំណេញរក្សាទុកក្នុងស្ថានភាពហិរញ្ញវត្ថុធម្មតា ដើម្បីត្រៀមទប់ទល់នៅក្នុងស្ថានភាពណាមួយដែលគ្រឹះស្ថានមានការខាតបង់ពីកត្តាផ្សេងៗ ខណៈដែលទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល គឺជាដើមទុនបន្ថែមដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាទុកសម្រាប់បំពេញការខាតបង់ ដែលបណ្តាលមកពីហានិភ័យជាប្រព័ន្ធ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបានតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តទ្រនាប់ដើមទុនខនស៊ើវេសិនកម្រិត ១,២៥% ចាប់ពីខែមករា ឆ្នាំ២០១៩ និងកម្រិត ២,៥% ចាប់ពីខែមករា ឆ្នាំ២០២០ ខណៈការអនុវត្តទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល នៅកម្រិត ០%។ និង
- អនុបាតគ្របខណ្ឌសន្ទនីយភាពត្រូវបានបង្កើនដល់កម្រិត ៩០% នៅខែមិថុនា ឆ្នាំ២០១៩ និងកម្រិត ១០០% នៅខែមករា ឆ្នាំ២០២០។ អនុបាតគ្របខណ្ឌសន្ទនីយភាពមានគោលបំណងឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធានាការទូទាត់បំណុលឬកាតព្វកិច្ចទូទាត់រយៈពេលខ្លី ដោយគ្រឹះស្ថានត្រូវរក្សាឱ្យបានគ្រប់គ្រាន់ គ្រប់ពេលវេលា និងជាប្រចាំនូវទ្រព្យសកម្មដែលងាយក្លាយជាសាច់ប្រាក់ ដើម្បីធានាការទូទាត់ទាំងប្រាក់បញ្ញើ និងការទូទាត់ផ្សេងៗ។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានតាមដានដោយយកចិត្តទុកដាក់លើហានិភ័យដែលអាចកើតចេញពីកំណើនឥណទានទិញផ្ទះ និងវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ។ ការអង្កេតមួយត្រូវបានធ្វើឡើងនៅតាមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីតាមដានស្ថានភាពសំពៀតឥណទានទិញផ្ទះ គោលនយោបាយឥណទាន និងជាពិសេស អនុបាតឥណទានធៀបនឹងទ្រព្យបញ្ចាំដែលជាសូចនាករមួយសម្រាប់វាស់វែងស្ថានភាពបំណុល។ លទ្ធផលអង្កេតបានបង្ហាញថា គ្រឹះស្ថានហិរញ្ញវត្ថុភាគច្រើនមានភាពប្រុងប្រយ័ត្នខ្ពស់ក្នុងការផ្តល់ឥណទាន ដោយអនុបាតឥណទានធៀបនឹងទ្រព្យបញ្ចាំជាទូទៅមានកម្រិតទាបជាង ៧០%។ ការអង្កេតនេះអាចផ្តល់ជាធាតុចូលបន្ថែមដល់ធនាគារជាតិនៃកម្ពុជាក្នុងការពិចារណាដាក់ឱ្យអនុវត្តអនុបាតឥណទានធៀបនឹងទ្រព្យបញ្ចាំដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនាពេលអនាគត សំដៅពង្រឹងយន្តការផ្តល់ឥណទាន និងកាត់បន្ថយហានិភ័យពីការផ្តល់ឥណទានច្រើនលើសលទ្ធភាពសង។

**ប្រអប់ ៖ វិធានការម៉ាក្រូប្រុងប្រយ័ត្នមួយចំនួនដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា**

ដើម្បីពង្រឹងភាពធន់និងកាត់បន្ថយហានិភ័យនៅក្នុងប្រព័ន្ធធនាគារ វិធានការម៉ាក្រូប្រុងប្រយ័ត្នមួយចំនួនត្រូវបានដាក់ចេញ ដើម្បីបង្កើនកម្រិតសន្ទនីយភាពនិងដើមទុននៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ៖

| វិធានការ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|
| ១-អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ៦០%<br>(កញ្ញា) | ៧០%<br>(កញ្ញា) | ៨០%<br>(កញ្ញា) | ៩០%<br>(មិថុនា) | ១០០%<br>(មករា) |
| ២-ដើមទុនចុះបញ្ជីអប្បបរមា | | ៥០%<br>(មីនា) | ១០០%<br>(មីនា) | | |
| ៣-ទ្រនាប់ដើមទុនខនស៊ើវេសិន<br>(Capital Conservation Buffer) | | | | ៥០%<br>(មករា) | ១០០%<br>(មករា) |
| ៤-អនុបាតទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល<br>(Countercyclical Capital Buffer Ratio) | | | 0%<br>(មីនា) | | |
| ៥-ចំណាត់ថ្នាក់ហានិភ័យឥណទាននិងសំវិធានធនលើអ៊ីមភែរមិន<br>(Impairment Provisioning) | | (ធ្នូ) | | | |

កំណត់ចំណាំ៖ ១-អនុបាតក្របខ័ណ្ឌសន្ទនីយភាពអប្បបរមាសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ; ២-ដើមទុនចុះបញ្ជីអប្បបរមាត្រូវបានកំណត់ដូចតទៅ៖ ៣០០ ប៊ីលានរៀល (៧៥ លានដុល្លារអាមេរិក) សម្រាប់ធនាគារពាណិជ្ជ, ៦០ ប៊ីលានរៀល (១៥ លានដុល្លារអាមេរិក) សម្រាប់ធនាគារឯកទេស, ១២០ ប៊ីលានរៀល (៣០ លានដុល្លារអាមេរិក) សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ, ៦ ប៊ីលានរៀល (១,៥ លានដុល្លារអាមេរិក) សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ; ៣-កម្រិតទ្រនាប់ដើមទុនខនស៊ើវេសិនត្រូវស្មើ ២,៥% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ; ៤-អនុបាតទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខលអាចត្រូវបានកំណត់ចាប់ពីកម្រិត 0% ទៅ ២,៥% នៃទ្រព្យសកម្មដែលបានថ្លឹងតាមកម្រិតហានិភ័យ; ៥-ចំណាត់ថ្នាក់ហានិភ័យឥណទាននិងសំវិធានធនលើអ៊ីមភែរមិន គឺជាផ្នែកមួយនៃការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យឥណទានដោយប្រុងប្រយ័ត្ន ដែលមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

## ៣.៤ ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចនិងវិស័យធនាគារ

ផលប៉ះពាល់ដែលអាចបណ្ដាលមកពីការដកប្រព័ន្ធអនុគ្រោះពន្ធ EBA មានទំហំតូចជាងការរំពឹងទុក ប៉ុន្តែបញ្ហាប្រឈមខ្លាំងបំផុតនាពេលនេះ គឺផលប៉ះពាល់នៃជំងឺកូវីដ១៩ដែលធ្វើឱ្យរាំងស្ទះដល់សកម្មភាពសេដ្ឋកិច្ច ហើយធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពក្នុងការសងបំណុលរបស់អ្នកខ្ចីប្រាក់និងប្រាក់ចំណូលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ កំណើនភ្ញៀវទេសចរត្រូវបានរំពឹងថានឹងថយចុះខ្លាំងនៅឆ្នាំ២០២០ ដែលអាចនឹងប៉ះពាល់ទៅដល់អនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន ដឹកជញ្ជូននិងគមនាគមន៍។ វិធានការរឹតត្បិតសកម្មភាពសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកនិងអឺរ៉ុប អាចនឹងជះ

ឥទ្ធិពលដល់ការនាំចេញរបស់កម្ពុជា ជាពិសេសការនាំចេញក្នុងវិស័យកម្មន្តសាល ដែលអាចបណ្ដាលឱ្យរោងចក្រមួយចំនួនត្រូវព្យួរការងារជាបណ្ដោះអាសន្ន។ ជាមួយគ្នានេះ វិស័យសំណង់និងអចលនទ្រព្យ ដែលមានកំណើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ អាចប្រឈមនឹងការផ្គត់ផ្គង់លើស និងការធ្លាក់ចុះវំហូរទុនវិនិយោគ។ ដូច្នេះ កំណើនឥណទានទៅកាន់វិស័យទាំងនេះត្រូវបានរំពឹងថានឹងថយចុះ ខណៈអនុបាតឥណទានមិនដំណើរការអាចនឹងកើនឡើង។ សម្រាប់អ្នកដែលប្រកបអាជីវកម្មក្រៅប្រព័ន្ធដែលមានការគាំពារតិចតួច អាចប្រឈមនឹងការធ្លាក់ចុះខ្លាំងនៃប្រាក់ចំណូល ស្របពេលដែលការផ្ញើរប្រាក់របស់ពលករនិងនិយោជិតពីក្រៅប្រទេសមកកម្ពុជា ក៏ត្រូវបានរំពឹងថានឹងធ្លាក់ចុះផងដែរ។ ប៉ុន្តែ វិស័យកសិកម្មរំពឹងថានឹងមានកំណើនខ្ពស់ជាងឆ្នាំ២០១៩បន្តិច ដោយសារការថមថយឥទ្ធិពលនៃគ្រោះធម្មជាតិ និងការវិលត្រឡប់របស់ពលករចំណាកស្រុកមួយចំនួន ដែលនឹងធ្វើឱ្យកម្លាំងពលកម្មក្នុងវិស័យនេះមានការកើនឡើង។

ប្រព័ន្ធធនាគារត្រូវបានរំពឹងថានឹងបន្តមានស្ថិរភាព ដែលឆ្លុះបញ្ចាំងតាមរយៈ៖ i/-ស្ថានភាពដើមទុន និងសន្ទនីយភាពរបស់ប្រព័ន្ធធនាគារមានកម្រិតល្អ ii/-អនុបាតក្របខ័ណ្ឌសន្ទនីយភាពមានកម្រិតខ្ពស់ iii/-អនុបាតឥណទានមិនដំណើរការបន្តមានកម្រិតទាប និង iv/-លទ្ធភាពស្វែងរកប្រាក់ចំណេញមានស្ថិរភាពល្អ។ ទោះយ៉ាងណា ដោយសារការរីករាលដាលជំងឺកូវីដ១៩ វិស័យធនាគារអាចប្រឈមនឹងហានិភ័យមួយចំនួនផងដែរ ដូចជា៖ i/-ការថមថយកំណើនឥណទាន ii/-ការថមថយការដាក់ប្រាក់បញ្ញើ iii/-ការកើនឡើងឥណទានរៀបចំឡើងវិញ iv/-ការថយចុះនៃប្រភពមូលនិធិពីខាងក្រៅ ដោយសារស្ថានភាពរឹតត្បិតនៃទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និង v/-ការថយចុះនៃវិស័យសំណង់និងអចលនទ្រព្យ។

ឆ្លើយតបនឹងបញ្ហានេះ រាជរដ្ឋាភិបាលបានដាក់ចេញវិធានការជាបន្តបន្ទាប់ដើម្បីបន្តគាំទ្រសកម្មភាពសេដ្ឋកិច្ច។ ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាក៏បានដាក់ចេញវិធានការបុរេសកម្មចាំបាច់មួយចំនួននៅក្នុងវិស័យធនាគារ រួមមាន៖ i/-ពន្យារពេលឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរក្សាកម្រិតទ្រនាប់ដើមទុនខនស៊ើរវេសិននៅត្រឹម ១,២៥% ii/-កាត់បន្ថយអត្រាការប្រាក់អប្បបរមានៃប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានាចំនួន ០,៥% ចំពោះគ្រប់ឥណទាន iii/-កាត់បន្ថយអត្រាការប្រាក់លើមូលបត្រអាចជួញដូរបានចារឹកជារៀលនិងជាដុល្លារអាមេរិកក្នុងកម្រិតសមស្រប iv/-កាត់បន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ចពី ៨% ចំពោះប្រាក់រៀល និង ១២,៥% ចំពោះរូបិយប័ណ្ណ មកត្រឹម ៧% ចំពោះប្រាក់រៀល និងរូបិយប័ណ្ណដើម្បីផ្ដល់សន្ទនីយភាពបន្ថែមដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរយៈពេល៦ខែ v/-ដាក់ចេញសារាចរណែនាំស្ដីពីការរៀបចំឥណទានឡើងវិញ និង vi/-កាត់បន្ថយកម្រិតអនុបាតក្របខ័ណ្ឌសន្ទនីយភាពក្នុងកម្រិតសមស្របតាមការចាំបាច់។ ការកាត់បន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ចបានបង្កើនសាច់ប្រាក់ក្នុងដៃរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រមាណ ១,៨ ប៊ីលានដុល្លារអាមេរិក ហើយការពន្យារពេលបំពេញទ្រនាប់ដើមទុនខនស៊ើរវេសិនបានផ្ដល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចផ្ដល់ឥណទានបន្ថែមប្រមាណ ៣ ប៊ីលានដុល្លារអាមេរិក។ ធនាគារជាតិនៃកម្ពុជា បានត្រៀមរួចរាល់ក្នុងការដាក់ចេញនូវវិធានការគាំទ្រដទៃទៀតស្របតាមស្ថានភាពជាក់ស្ដែង។

## **ឧបសម្ព័ន្ធ ៖ វិធីសាស្ត្រគណនាសូចនាករសម្ពាធទីផ្សារប្តូរប្រាក់** (EMP)

សូចនាករសម្ពាធទីផ្សារប្តូរប្រាក់ (EMP) ត្រូវបានប្រើដើម្បីវិភាគសម្ពាធមកលើអត្រាប្តូរប្រាក់នៅក្នុងទីផ្សារ ដោយពិចារណាលើការផ្លាស់ប្តូរប្រាក់បម្រុងអន្តរជាតិប្រចាំខែ (តំណាងឱ្យការធ្វើអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់របស់ធនាគារកណ្តាល) និងការប្រែប្រួលអត្រាប្តូរប្រាក់នៅក្នុងទីផ្សារ។ ការគណនាអាចត្រូវបានបែងចែកជាពីរជំហាន៖ i/-ការគណនា EMP និង ii/-ការកំណត់កម្រិតគោលនៃ EMP។

- **ជំហានទី១ ៖ ការគណនា EMP**

$$EMP_{it}=\left(\frac{e_{it}-e_{it-1}}{e_{it-1}}\right)*100-\left(\frac{\sigma_e}{\sigma_{fxr}}\right)\left(\frac{fxr_{it}-fxr_{it-1}}{fxr_{it-1}}\right)*100$$

ដែល $e_{it}$ ជាអត្រាប្តូរប្រាក់នៅក្នុងខែ t, $e_{it-1}$ ជាអត្រាប្តូរប្រាក់នៅខែ t-1, $\sigma_e$ ជា standard deviation នៃការប្រែប្រួលអត្រាប្តូរប្រាក់ខែលើខែ, $\sigma_{fxr}$ ជា standard deviation នៃការប្រែប្រួលទុនបម្រុងអន្តរជាតិខែលើខែ, $fxr_{it}$ ជាទុនបម្រុងអន្តរជាតិនៅខែ t និង $fxr_{it-1}$ ជាទុនបម្រុងអន្តរជាតិនៅខែ t-1

- **ជំហានទី២ ៖ ការកំណត់កម្រិតគោល (Threshold) នៃ EMP**

$$\textbf{Threshold} = \mu_{EMP} + \varphi\sigma_{EMP}$$

ដែល $\mu_{EMP}$ ជាកម្រិតមធ្យមនៃ EMP, $\sigma_{EMP}$ ជា standard deviation នៃ EMP; $\varphi$ ជាមេគុណនៃ $\sigma_{EMP}$ (ជាកម្រិតទាបនិងខ្ពស់នៃ EMP ដែលគណនាតាមរយៈរូបមន្ត percentile)

**សម្គាល់៖** ក្នុងបរិការណ៍សេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ នៅពេលដែលសូចនាករ EMP ប្រែប្រួលលើសកម្រិតគោលខាងក្រោមឬខាងលើ នោះមិនមានន័យថាប្រទេសកម្ពុជាជួបវិបត្តិរូបិយវត្ថុទេ។ វាបង្ហាញពីសម្ពាធមកទីផ្សារប្តូរប្រាក់ ដែលបានឆ្លុះបញ្ចាំងពីការធ្លាក់ចុះនៃទុនបម្រុងអន្តរជាតិនិង/ឬសម្ពាធនៃការធ្លាក់ថ្លៃរូបិយវត្ថុ (ប្រសិនបើ EMP កើនឡើងខ្ពស់ជាងកម្រិតគោលខាងលើ) ឬការគរពូនទុនបម្រុងអន្តរជាតិនិង/ឬសម្ពាធនៃការឡើងថ្លៃរូបិយវត្ថុ (ប្រសិនបើ EMP ធ្លាក់ចុះទាបជាងកម្រិតគោលខាងក្រោម)។